ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដីនៅក្នុងឃុំទំនប់រលក

## ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ



រៀបចំដោយ : គណៈកម្មាធិការកសាងផែនការ និងថវិកា និងក្រុមប្រឹក្សាឃុំ

គាំទ្របច្ចេកទេសដោយ : សមាសភាគរៀបចំដែនដី/ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

គាំទ្រមូលនិធិដោយ :អង្គការ DANIDA-DFIT-NZAid

ឆ្នាំ២០០៩

# មាតិកា


អារម្ភកថា ..........

សេចក្តីផ្តើម ..........

ជំពូក១ ព័ត៌មាន និងទិន្នន័យសំរាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ .......... ១

១.១ ស្ថានភាពទូទៅ .......... ១

១.១.១ ទីតាំងរដ្ឋបាល .......... ១

១.១.២ ប្រជាសាស្ត្រ .......... ២

១.១.៣ ភាពគ្មានដីធ្លី .......... ៣

១.១.៤ ស្ថានភាពសេដ្ឋកិច្ច .......... ៤

១.១.៥ ស្ថានភាពអប់រំ និងសិក្សាធិការ .......... ៦

១.១.៦ ស្ថានភាពសុខាភិបាល .......... ៨

១.១.៦.១ ផ្នែកសុខាភិបាល .......... ៨

១.១.៦.២ ការផ្គត់ផ្គង់ទឹកស្អាត .......... ៨

១.២ ស្ថានភាពភូមិសាស្ត្រ .......... ៩

១.២.១ ទីតាំងភូមិសាស្ត្រ .......... ៩

១.២.២ អាកាសធាតុ .......... ១០

១.២.៣ ហេដ្ឋារចនាសម្ព័ន្ធ .......... ១១

១.៣ ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន .......... ១៦

១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី .......... ១៦

១.៣.២ ស្ថានភាពនៃការកាន់កាប់ដី .......... ១៩

១.៣.៣ ផលិតកម្មកសិកម្ម .......... ១៩

១.៣.៣.១ ផលិតកម្មដំណាំស្បៀង .......... ១៩

១.៣.៤ ធនធានធម្មជាតិ .......... ១៩

១.៣.៤.១ ធនធានព្រៃឈើ .......... ២០

១.៣.៤.២ ធនធានជលផល .......... ២១

១.៣.៥ ធនធានរ៉ែ .......... ២២

១.៤ ទីផ្សារ និងខ្សែចង្វាក់ផលិតផល .......... ២២

១.៤.១ ទីផ្សារ និងតម្លៃផលនេសាទ .......... ២២

១.៤.២ ខ្សែសង្វាក់ និងចរាចរផលិតផល .......... ២៣

១.៤.៣ ឱកាស និងឧបស័គ្គ ..................................................... ២៣
ជំពូក២ ការវិភាគពីឧបស័គ្គ តម្រូវការសំរាប់អនាគត និងសក្តានុពល ............................................ ២៥
២.១ តំបន់រសើប ..................................................... ២៥
២.២ ការប្រឈម / ឧបស័គ្គ ..................................................... ២៦
២.២.១ ការប្រឈមដោយធម្មជាតិ ..................................................... ២៦
២.២.២ ការប្រឈមដោយការអភិវឌ្ឍន៍ដែលពុំមានចិរភាព ..................................................... ២៧
២.២.៣ ដោយគំរោងវិនិយោគ ..................................................... ២៩
២.៣ កំណត់តម្រូវការនៃការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្ត្រឃុំ ..................................................... ២៩
២.៤ តម្រូវការសំរាប់អនាគត ..................................................... ៣០
២.៤.១ ប្រជាសាស្ត្រ ..................................................... ៣០
២.៤.១.១ អត្រាកំណើន ..................................................... ៣០
២.៤.១.២ ការធ្វើចំណោលប្រជាសាស្ត្រ ..................................................... ៣០
២.៤.២ តម្រូវការដីសំរាប់លំនៅដ្ឋាន ..................................................... ៣១
២.៤.៣ តម្រូវការដីសំរាប់កសិកម្ម ..................................................... ៣២
២.៤.៤ តម្រូវការសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ..................................................... ៣២
២.៤.៤.១ ដីព្រៃឈើ ..................................................... ៣២
២.៤.៤.២ ធនធានទឹក ..................................................... ៣៣
២.៤.៥ តម្រូវការដីសំរាប់ ហេដ្ឋារចនាសម្ព័ន្ធ ..................................................... ៣៣
២.៤.៥.១ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រព័ន្ធសង្គម ..................................................... ៣៣
២.៤.៥.២ តម្រូវការដីសាលារៀន ..................................................... ៣៤
២.៤.៥.៣ សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត ..................................................... ៣៥
ជំពូក៣ ផែនការប្រើប្រាស់ដីពេលអនាគត ..................................................... ៣៩
៣.១ ស្ថានភាពដី សក្តានុពលដី និងតម្រូវការដី ..................................................... ៣៩
៣.១.១ ស្ថានភាពដីទូទៅ និងសក្តានុពល ..................................................... ៣៩
៣.១.២ តម្រូវការដីតាមប្រភេទ ..................................................... ៣៩
៣.២ ការបែងចែកដីតាមតម្រូវការប្រើប្រាស់ ..................................................... ៣៩
៣.២.១ ការវិភាគអន្តរៈអំពើ ..................................................... ៤០
៣.២.២ ផែនទីប្រើប្រាស់ដីអនាគត ..................................................... ៤០
៣.២.៣ ការបរិយាយការប្រើប្រាស់តាមក្បាលដី ..................................................... ៤១

ឧបសម្ព័ន្ធ១ : ការពិពណ៌នាអំពី ស្ថានភាពការប្រើប្រាស់ដីបច្ចុប្បន្ន

ឧបសម្ព័ន្ធ២ : ស្ថានភាពនៃការគ្រប់គ្រងនិងកាន់កាប់ដីបច្ចុប្បន្ន

ឧបសម្ព័ន៣ : បញ្ហាពាក់ព័ន្ធក្នុងការប្រើប្រាស់ដី

ឧបសម្ព័ន៤ : ក្របខ័ណ្ឌអភិវឌ្ឍន៍

ឧបសម្ព័ន៥ : បញ្ជីគំរោង

ឧបសម្ព័ន៦ : ផែនទីប្រើប្រាស់ដីលំអិត

ឧបសម្ព័ន៧ : ផែនទីប្រើប្រាស់ដីសាមញ្ញ

ឧបសម្ព័ន៨ : ផែនទីប្រើប្រាស់ដីពេលអនាគត ឆ្នាំ២០០៩-២០២២

# <u>អារម្ភកថា</u>

របាយការណ៍ស្តីអំពីផែនការប្រើប្រាស់ដីនៅក្នុងឃុំទំនប់រលកស្រុកស្ទឹងហាវខេត្តព្រះសីហនុ រយៈពេល១៥ឆ្នាំ ត្រូវបាន រៀបចំឡើងដោយក្រុមប្រឹក្សាឃុំទំនប់រលក និងមានការចូលរួមពីគណៈកម្មាធិការកសាងផែនការនិងថវិកា និងប្រជាពលរដ្ឋ ដោយមានកិច្ចសហការពីក្រុមអ្នកសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីស្រុកស្ទឹងហាវ(D-LUP) ក្រុមអ្នកសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីខេត្តព្រះសីហនុ(P-LUP) និងគាំទ្របច្ចេកទេសពីក្រុមការងារសមាសភាគរៀបចំដែនដី(LandManagementComponent) របស់អគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម នៃក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ក្រោមការជួយឧបត្ថម្ភថវិកាពីអង្គការDANIDA/DFID-NZAid តាមរយៈស្ថានទូតដាណឺម៉ាកប្រចាំនៅក្នុងប្រទេសកម្ពុជា ។

គោលបំណងចំបងនៃផែនការប្រើប្រាស់ដីនៅក្នុងឃុំទំនប់រលកនេះ ជាត្រីវិស័យតំរង់ទិសដល់ការអភិវឌ្ឍន៍ និងដើម្បីគាំទ្រដល់ដំណើរការកសាងផែនការអភិវឌ្ឍន៍កម្មវិធីវិនិយោគឃុំសង្កាត់អោយចំទិសដៅ ព្រមទាំងតំរូវការរបស់ប្រជាពលរដ្ឋស្របតាម គោលនយោបាយកាត់បន្ថយភាពក្រីក្រ និងគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ សំដៅពង្រឹងអភិបាលកិច្ចល្អរបស់រាជរដ្ឋាភិបាលដើម្បីលើកស្ទួយសេដ្ឋកិច្ចនិងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង ។

ក្នុងនាមក្រុមប្រឹក្សាឃុំអាណត្តិទី២ សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅដល់គណៈកម្មាធិការកសាងផែនការនិងថវិកា ជនបង្គោល ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមយ៉ាងសស្រាក់សស្រាំដោយបានលើកឡើងពីបញ្ហា មូលហេតុជាក់ស្តែងនានាដែលបានជួបប្រទះកន្លងមក និងតំរូវការអភិវឌ្ឍន៍ ជាពិសេសចំពោះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអង្គការDANIDA/DIFID-NZAidតាមរយៈស្ថានទូតដាណឺម៉ាកប្រចាំនៅព្រះរាជាណាចក្រកម្ពុជាដែលបានផ្តល់ ថវិកាជំនួយសំរាប់ដំណើរការរៀបចំផែនការប្រើប្រាស់ដីនេះចាប់តាំងពីការចាប់ផ្តើមរហូតដល់ទីបញ្ចប់ ។ ជាមួយគ្នានេះក៏សូមថ្លែងអំណរគុណផងដែរ ដល់ក្រុមការងាររបស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់និងសុរិយោដីខេត្តព្រះសីហនុដែលបានជួយសម្របសម្រួលក្នុងការរៀបចំផែនការនេះអោយបានទទួលបានជោគជ័យនឹងក៏សូមថ្លែងអំណរគុណពីការចូលរួមរបស់មន្ទីរពាក់ព័ន្ធនានាជុំវិញខេត្ត ជាពិសេសអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ខណ្ឌរដ្ឋបាលព្រៃឈើ ខណ្ឌរដ្ឋបាលជលផល និងមន្ទីរកសិកម្ម មន្ទីរបរិស្ថាន និងមន្ទីរពាក់ព័ន្ធនានាជុំវិញខេត្ត ។

ក្រុមប្រឹក្សាឃុំទំនប់រលកទាំងអស់គ្នាសង្ឃឹមថា សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់នឹងបានយល់ដឹងអំពីស្ថានភាពនិងតម្រូវការព្រមទាំងបញ្ហាប្រឈមទាំងឡាយពាក់ព័ន្ធនឹងការប្រើប្រាស់ដីក្នុងដំណើរការអភិវឌ្ឍឃុំទំនប់រលកហើយនឹងបង្ហាញនូវទឹកចិត្តសម្បុរសធមិដ៏ថ្លៃថ្លាតាមរយៈការចូលរួមផ្តល់នូវសំភារៈ និងថវិកាសំរាប់គាំទ្រការអនុវត្តន៏ផែនការប្រើប្រាស់ដីថ្មីនេះដើម្បីចូលរួមចំណែកអភិវឌ្ឍន៍ មូលដ្ឋានតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ប្រកបដោយជោគជ័យ ។

ធ្វើនៅទំនប់រលក ថ្ងៃទី...១៦...ខែ.....ធ្នូ........ឆ្នាំ ២០០៩

មេឃុំ

ឡាន- ចិន

# សេចក្តីផ្តើម

ឃុំទំនប់រលកជាឃុំមួយរបស់ស្រុកស្ទឹងហាវខេត្តព្រះសីហនុ ដែលមានទីតាំងស្ថិតនៅខាងជើងឈៀងខាងកើតរបស់ស្រុកស្ទឹងហាវ ។ កាលពីឆ្នាំ១៩៧៩ ឃុំនេះនៅជាសង្កាត់មួយរបស់ក្រុងកំពង់សោម ។ នៅអំឡុងខែមេសា ឆ្នាំ១៩៨៤ យោងតាមសេចក្តីសំរេចរបស់គណៈកម្មាធិការប្រជាជនក្រុងកំពង់សោមបានបង្កើតតំបន់ថ្មីឈ្មោះថា "សង្កាត់ទំនប់រលក" ។

បច្ចុប្បន្នសង្កាត់ទំនប់រលកបានប្តូរឈ្មោះជាឃុំ ទំនប់រលក ដោយមានភូមិចំនួន ៤ មានផ្ទៃដីសរុបក្នុងការប៉ាន់ស្មាន៩.២៣២ហិកតា ដែលមានទីតាំងនៅតំបន់ភ្នំ ខ្ពង់រាប និង ក្បែរសមុទ្រ ហើយភាគច្រើនសាងសង់លំនៅដ្ឋានក្បែរផ្លូវ ។

ដោយឃុំនេះមានព្រំប្រទល់ជាប់នឹងសមុទ្រធ្វើអោយប្រជាពលរដ្ឋមានសក្តានុពលវិស័យ ជលផល កសិកម្ម ចិញ្ចឹមសត្វ តែពុំមានសក្តានុពលចំពោះហេដ្ឋារចនាសម្ព័ន្ធ ទោះបីឃុំនេះនៅឆ្ងាយពីទីរួមខេត្តក៏ដោយ ក៏រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់កសាងបាននូវសមិទ្ធិផលជាច្រើនដូចជាៈ ផ្លូវកៅស៊ូ ផ្លូវបេតុង ផ្លូវគ្រួសក្រហម, ស្ពាន,លូ, ប្រឡាយអាងទឹក ។ល។ ឆ្លងតាមសមិទ្ធផលនេះ នៅឆ្នាំ២០០៩ ក្រុមប្រឹក្សាឃុំនិងគណៈកម្មាធិការកសាងផែនការ និងថវិកាបានរៀបចំផែនការប្រើប្រាស់ដីនៅ ក្នុងឃុំអោយស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សំដៅដល់ការធ្វើផែនការប្រើប្រាស់ដីក្នុងឃុំទាំងមូល ទាំងដីសាធារណៈរបស់រដ្ឋ និង ដីកម្មសិទ្ធិឯកជន ។ ការរៀបចំផែនប្រើប្រាស់ដីក្នុងឃុំមានគោលបំណង ៖

- រៀបចំផែនការគ្រប់គ្រង និងប្រើប្រាស់ធនធានដី និង ធនធានធម្មជាតិប្រកបដោយប្រសិទ្ធិភាព
- កាត់បន្ថយទំនាស់ក្នុងការប្រើប្រាស់ដីធ្លី
- គាំទ្រកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមប្រកបដោយនិរន្តរភាព និងសមធម៌
- រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ
- សំរេចអោយបាននូវការប្រើប្រាស់ដីក្នុងឃុំ ស្របតាមស្ថានភាពដីជាក់ស្តែង និងសក្តានុពលធម្មជាតិនៃដី
- ឆ្លើយតបចំពោះសេចក្តីត្រូវការរបស់អាជ្ញាធរនានា និងរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ
- ជួយការពារធនធានដីនិងធនធានធម្មជាតិផ្សេងៗទៀតមិនអោយបាត់បង់គុណភាពនិងមិនអោយប្រើប្រាស់ខុសទិសដៅ
- រួមចំណែកគ្រប់គ្រងដីរដ្ឋ ដែលមានក្នុងឃុំអោយបានល្អប្រសើរតាមតួនាទីជាភ្នាក់ងារ តំណាងរបស់រដ្ឋ
- ស្វែងរកការគាំទ្របច្ចេកទេសពីស្ថាប័ន អង្គភាពនានា និង ពីផ្នែកឯកជន ក្នុងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ ។

ពិនិត្យជារួម ផែនការប្រើប្រាស់ដីឃុំនេះជាឧបករណ៍មួយដ៏មានសារៈសំខាន់ ដែលជួយដល់ក្រុមប្រឹក្សាឃុំក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់ក្នុងការរួមចំណែកដល់ការគ្រប់គ្រង និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាពនិងសមធម៌ព្រោះដីធ្លីជាកត្តាស្នូលក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជីវភាពប្រជាពលរដ្ឋក្នុងឃុំទាំងមូល ។

ដូច្នេះក្រោយពីបានរៀបចំផែនការប្រើប្រាស់ដីនេះរួចធ្វើអោយឃុំមានទិសដៅច្បាស់លាស់ក្នុងការធ្វើការងារ

អភិវឌ្ឍន៍ឬសំរាប់គំរោងសកម្មភាពសំរាប់អាណត្តិរបស់ខ្លួននៅថ្ងៃខាងមុខមិនត្រឹមតែប៉ុណ្ណោះ វាជាយុទ្ធសាស្ត្រមួយសំរាប់អាណត្តិបន្តបន្ទាប់រយៈពេល១៥ ឆ្នាំក្រោយ ដោយផ្អែកលើបញ្ហា មូលហេតុ ដំណោះស្រាយដែលបាន លើកឡើង និង ធ្វើការប្រៀបធៀបទៅនឹង លទ្ធផលជាក់ស្តែងដែលបានកើតមានឡើងនៅក្នុងឃុំទាំងមូល ។

# ជំពូក១

# ព័ត៌មាន និងទិន្នន័យសម្រាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំទំនប់រលក

## ១.១ ស្ថានភាពទូទៅ

បានជាគេហៅឈ្មោះឃុំនេះថា ឃុំទំនប់រលក ពីព្រោះនៅកំឡុងខែមេសាឆ្នាំ ១៩៨៤ យោងតាមសេចក្តីសំរេចរបស់គណៈកម្មាធិការក្រុងកំពង់សោមបានបង្កើតតំបន់ថ្មីមួយឈ្មោះខណ្ឌស្ទឹងហាវ ដែលមានសង្កាត់ចំនួន ៣ មកពីសង្កាត់ទំនប់រលក សង្កាត់អូរត្រេះ សង្កាត់កំពេញ ក្នុងក្រុងកំពង់សោម មកជាចំណុះអោយខណ្ឌស្ទឹងហាវ ក្រុងកំពង់សោម។ បច្ចុប្បន្នសង្កាត់ទំនប់រលកបានប្តូរឈ្មោះជាឃុំទំនប់រលក យោងលើអនុក្រឹត្យលេខ.០៧អ.ន.ក្រ.ប.ក.ចុះថ្ងៃទី.០៩ ខែ មករា.ឆ្នាំ ២០០៩។

### ១.១.១ ទីតាំងរដ្ឋបាល

| | | |
|---|---|---|
| ខេត្ត | ព្រះសីហនុ | |
| ស្រុក/ក្រុង | ស្ទឹងហាវ | |
| ឃុំ/សង្កាត់ | ទំនប់រលក | លេខកូដ : ១៨ ០៣ ០៣ |
| ចំនួនភូមិ | ០៤ ភូមិ ( ភូមិ១ ភូមិ២ ភូមិ៣ និង ភូមិ៤ ) | |

ឃុំទំនប់រលក គឺជាឃុំមួយក្នុងចំណោមឃុំទាំង ៣នៃស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ឃុំនេះមានទីតាំងស្ថិតនៅផ្នែកខាងជើងឈៀងខាងកើត នៃស្រុកស្ទឹងហាវ មានចំងាយប្រមាណ ១៦០០ម៉ែត្រពីទីរួមស្រុក និងស្ថិតនៅខាងជើងនៃទីរួមខេត្តព្រះសីហនុមានចំងាយប្រមាណ ២៨ គីឡូម៉ែត្រពីទីរួមខេត្ត។

ឃុំទំនប់រលក មានផ្ទៃដី ៥.២៣២.ហិកតា (តាមព័តិមានពីឃុំ) និង ៥១២៥.១៤៣៤ហិចតា តាមទិន្នន័យ GIS ។

ឃុំ ទំនប់រលក មានព្រំប្រទល់:

- ខាងជើងទល់នឹងសមុទ្រ
- ខាងត្បូងទល់នឹងឃុំអណ្តូងថ្ម ឃុំអូរត្រេះ
- ខាងកើតទល់នឹងឃុំជើងគោ សំរ៉ុង អណ្តូងថ្ម ស្រុកព្រៃនប់
- ខាងលិចទល់នឹងសមុទ្រ ឃុំកំពេញ ឃុំអូរត្រេះ ។




### ១.១.២ ប្រជាសាស្ត្រ

ឃុំទំនប់រលក មានប្រជាពលរដ្ឋរស់នៅ ចំនួន ៧១៨៤ នាក់ ប្រុសមានចំនួន ៣៥៤៨ នាក់ និងស្រី ៣៦៣៦ នាក់ ត្រូវជា ២០១៧ គ្រួសារបែងចែកជា ៥៤ ក្រុម ដែលមានស្ត្រីមេម៉ាយជាមេគ្រួសារមានចំនួន ២៥៩ គ្រួសារ ។

**ក.តារាងស្ថិតិប្រជាជន ឃុំទំនប់រលក ឆ្នាំ២០០៨ តាមក្រុមអាយុ**

| ស្ថិតិតាមក្រុមអាយុ | ប្រុស | ស្រី | សរុប | ផ្សេងៗ |
|---|---|---|---|---|
| អាយុក្រោម០៥ឆ្នាំ | ៣០០ | ៣១៧ | ៦១៧ | |
| អាយុ ០៥ឆ្នាំ | ៩៤ | ៩២ | ១៨៦ | អាយុចូលរៀនមត្តេយ្យ |
| អាយុពី ៦-១១ឆ្នាំ | ៤៧០ | ៤៦២ | ៩៣២ | អាយុចូលរៀនបឋមសិក្សា |
| អាយុពី ១២-១៤ឆ្នាំ | ២៥៥ | ២៨៥ | ៥៤០ | អាយុចូលរៀនអនុវិទ្យាល័យ |
| អាយុពី ១៥-១៧ឆ្នាំ | ២៨៨ | ២៧៩ | ៥៦៧ | អាយុចូលរៀនវិទ្យាល័យ |
| អាយុពី ១៨-២៤ឆ្នាំ | ៦៣២ | ៦២៤ | ១២៥៦ | អាយុចូលរៀនមហាវិទ្យាល័យ |
| អាយុពី ២៥-៦០ឆ្នាំ | ១៣៦០ | ១៤០៤ | ២៧៦៤ | អាយុពេញពលកម្ម |
| អាយុពី ៦១ឆ្នាំឡើងទៅ | ១៤៩ | ១៧៣ | ៣២២ | អាយុចូលនិវត្តន៍ |
| ប្រជាជនសរុប | ៣៥៤៨ | ៣៦៣៦ | ៧១៨៤ | |
| ចំនួនគ្រួសារសរុប | ១៣៣៧ | | | |
| ទំហំគ្រួសារមធ្យម | **៥នាក់/គ្រួសារ** | | | |

**អត្រាកំណើនមធ្យម** ( **កំណើនធម្មជាតិ**)

| ចំនួនគ្រួសារ/ប្រជាជន | ចំនួនគ្រួសារ/ប្រជាជនតាមឆ្នាំ | | | | | កំណើនប្រជាសាស្ត្រ | |
|---|---|---|---|---|---|---|---|
| | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | កំណើនមធ្យម | កំណើនឆ្នាំ |
| ចំនួនគ្រួសារសរុប | ១៤៨៥ | ១៤១៥ | ១៣៥២ | ១៣៧៥ | ១៣៣៧ | - | - |
| អត្រាកំណើនគ្រួសារ | | -៥% | -៤% | ២% | -៣% | ៣% | ៦១ |
| ចំនួនប្រជាជនសរុប | ៨០៥៨ | ៧៧៤៦ | ៧២៥៦ | ៧៣០៣ | ៧១៨៤ | - | - |
| អត្រាកំណើនប្រជាជន | | -៤% | -៦% | ១% | -២% | ១% | ១០១ |

- យោងតាមតារាងខាងលើឆ្នាំ ២០០៥ - ២០០៦ ប្រជាជន -៥% ទៅ -៤% ។

**ខ.ដង់ស៊ីតេ និងរបាយដង់ស៊ីតេ**

-ដង់ស៊ីតេ ២៧៦.៤៣ នាក់/គម២ ( ទិន្នន័យផ្ទៃដីឃុំ )

-ដង់ស៊ីតេ ២៧២.៤១ នាក់/គម២ ( ទិន្នន័យផ្ទៃដីGIS)

**គ.ជនជាតិ**

ជនជាតិឥស្លាមមានចំនួន ២ គ្រួសារ សរុបចំនួន ១០ នាក់ ។

-វៀតណាមមានចំនួន១២គ្រួសារ សរុបចំនួន ៥០ នាក់ ។

**ឃ.ជំនឿសាសនា ប្រពៃណី ទំនៀមទំលាប់**

ឃុំទំនប់រលកពុំមានវត្តទេ ។

-ប្រជាពលរដ្ឋក្នុងឃុំទំនប់រលក កាន់ព្រះពុទ្ធសាសនា ចំនួនប្រជាជនប្រមាណ ៩០%រាល់ថ្ងៃសីល ថ្ងៃបុណ្យទៅវត្តពោធិ៍មានជយ័ ។

-អ្នកកាន់សាសនាឥស្លាម ១%ប្រជាពលរដ្ឋដែលកាន់សាសនាឥស្លាមទៅ សារ៉ាវនៅ ស្រុកព្រៃនប់ ។

-គ្រីស្តសាសនាមានវិហារ ១ កន្លែង មានប្រជាពលរដ្ឋប្រមាណ ៩%ប្រារព្ធរាងរាល់ថ្ងៃសៅរ៍ អាទិត្យ ។

**ង.ចំណូល និងចំណាកស្រុក**

| បរិយាយ | សរុប ( នាក់ ) | ស្រី ( នាក់ ) | ផ្សេងៗ |
|---|---|---|---|
| ចំណូល | ២៨ | ១៣ | ព័តិមាននគរបាលប៉ុស្តិ៍ ឆ្នាំ ២០០៩ |
| ចំណាក | ៣៣៦ | ១៥៥ | ព័តិមានស្ថានភាពឃុំ ឆ្នាំ ២០០៩ |

ប្រភពឯកសារស្ថានភាពឃុំឆ្នាំ ២០០៩ ។

### ១.១.៣ ភាពគ្មានដីធ្លី

- ប្រជាពលរដ្ឋគ្មានដីលំនៅដ្ឋានផ្ទាល់ខ្លួន១១២ គ្រួសារ គ្រួសារប្រភេទនេះ បច្ចុប្បន្នត្រូវបានប្រកបរបរដោយការស៊ីឈ្នួល បកក្តាម រើសបង្គារ ចុះទូកនេសាទសមុទ្រ ។

- ប្រជាពលរដ្ឋសាងសង់លំនៅដ្ឋានលើចំណីព្រែក និងចំណីឆ្នេរសមុទ្រ មានចំនួន ២៣៨គ្រួសារ ភាគរយ ប្រកបរបរ ចុះទូកសមុទ្រ( យោងតាមការសាកសួរមេភូមិ) ។

- ប្រជាពលរដ្ឋមានដីលំនៅដ្ឋាន តែគ្មានដីដាំដំណាំមានចំនួន ៣០គ្រួសារបកបរបរ ចុះទូកនេសាទសមុទ្រ។ (ឯកសារស្ថានភាពឃុំឆ្នាំ ២០០៩) ។

តារាងចំនួនគ្រួសារគ្មានដី និងមានដីមិនគ្រប់គ្រាន់

| ល.រ | បរិយាយ | ចំនួនគ្រួសារ | ភាគរយ% | ផ្សេងៗ |
|---|---|---|---|---|
| ១ | គ្មានដីលំនៅដ្ឋានផ្ទាល់ខ្លួន | ១១២ | ១.៥០% | |
| ២ | សាងសង់លើលំនៅដ្ឋាននៅលើចំណីព្រៃ និងចំណីឆ្នេរសមុទ្រ | ២៣៨ | ៣.៣១% | |
| ៣ | ប្រជាពលរដ្ឋមានដីលំនៅដ្ឋាន តែគ្មានដីចំការ | ៣០ | ០.៤១% | |

### ១.១.៤ **ស្ថានភាពសេដ្ឋកិច្ច**

ប្រជាពលរដ្ឋឃុំទំនប់រលកប្រមាណ ៥៣.៦៩% ប្រកបរបរនេសាទ និង មុខរបរផ្សេងៗទៀត ដូចជា ដាំដំណាំរយៈពេលវែង ដាំដំណាំរយៈពេលខ្លី មន្ត្រីរាជការ ធ្វើសិប្បកម្ម លក់ដូរ ជាងជួសជុល ចិញ្ចឹមសត្វ ដាំបន្លែ អនុផលព្រៃឈើ ជំនួញ ដឹកជញ្ជូន និងសេវាកម្ម ។

**ក.តារាងប្រភពចំណូលចំបង និង បន្ទាប់បន្សំ**

| ល.រ | ប្រភេទមុខរបរ | ចំនួនគ្រួសារ | | ផ្សេងៗ |
|---|---|---|---|---|
| | | ចំនួន | ភាគរយ (%) | |
| ១ | **ចំនួនគ្រួសារមានមុខរបរចំបង** | ១៣៨៩ | ៦៨.៨៦% | |
| ២ | ចំនួនគ្រួសារនេសាទ | ១០៦៣ | ៥៣.៦៩% | ត្រី ក្តាម បង្គា មឹក ខ្យង |
| ៣ | ដាំដំណាំរយៈពេលវែង | ១០៤ | ៥.១៦% | ស្វាយ,ដូង, ខ្នុរ,មាន. |
| ៤ | ដាំដំណាំរយៈពេលខ្លី | ១០០ | ៤.៩៦% | ចេក ល្ហុង |
| ៥ | ដាំដំណាំបន្លែ | ៣៤ | ១.៦៩% | ត្រកួន ,ស្ពៃ ,ត្រសក់,ត្រប់... |
| ៦ | ចិញ្ចឹមសត្វ | ៨៨ | ៤.៣៦% | មាន់ ទា គោ ជ្រូក.. |
| ៧ | ចំនួនគ្រួសារមានមុខរបរបន្ទាប់បន្សំ | ៦២៨ | ៣១.១៤% | |
| ៨ | អនុផលព្រៃឈើ | ១ | ០.០៥% | កាប់កូនឈើ វល្លិ៍ ផ្សូង |
| ៩ | កញ្ចក់អាលុយមីញ៉ូម | ៣ | ០.១៥% | |

| | | | | |
|---|---|---|---|---|
| ១០ | គ្រឿងបរិភោគ | ២៦ | ១.២៩% | |
| ១១ | សិប្បកម្មផ្សេងៗ | ២ | 0.១0% | សង្ហារឹម ផ្តៅ កញ្ជក់ |
| ១២ | មុខរបរជំនួញ | ១១៣ | ៥.៦0% | តាក់ស៊ី ម៉ូតូ កាត់សក់ |
| ១៣ | មុខរបរជាង | ៦៥ | ៣.២២% | ជាងជួសជុលម៉ូតូ ម៉ាស៊ីន |
| ១៤ | ដឹកជញ្ជូន | ១០៦ | ៥.២៦% | ទំនិញ អ្នកដំណើរ |
| ១៥ | សេវាកម្មផ្សេងៗ | ៣១០ | ១៥.៣៧% | អ៊ុតសក់ ធ្វើក្រចក |

ប្រភពទិន្នន័យស្ថានភាពឃុំឆ្នាំ ២០០៨។

ប្រជាជនមានប្រភពចំណូលសំខាន់ នេសាទ ។

**ខ.ចំណូល និង ចំណាយ**

ចំណូល និងចំណាយជាមធ្យម ប្រចាំថ្ងៃ និងប្រចាំឆ្នាំរបស់ប្រជាពលរដ្ឋ

| បរិយាយ | ចំណូល/ថ្ងៃ | ចំណាយ/ថ្ងៃ | ចំណូល/ឆ្នាំ | ចំណាយ/ឆ្នាំ |
|---|---|---|---|---|
| ប្រជាពលរដ្ឋ(នាក់/ថ្ងៃ) | ៤000-៤៥00 | ៣000-៣៥00 | ១.៦២៥.000 | ១.២៧៧.៥00 |

ប្រជាពលរដ្ឋចំណាយលើស្បៀងអាហារ សំលៀកបំពាក់ ឧបករណ៏ប្រើប្រាស់ថ្នាំព្យាបាល សម្ភារះសិក្សា និងពិធីបុណ្យផ្សេងៗ។

**គ.ស្ថានភាពបំណុល អត្រាការប្រាក់**

ប្រជាពលរដ្ឋក្នុងឃុំទំនប់រលកប្រមាណ ១៨.៣២%បានកំចីប្រាក់ពីធនាគារ អេស៊ីលីដា(ប្រភពក្រុមប្រឹក្សាឃុំ) ។

**អត្រា ការប្រាក់**

| បរិយាយ | អត្រា/ឆ្នាំ |
|---|---|
| កម្ចីប្រាក់រៀល | ២.៧% |
| កម្ចីប្រាក់ដុល្លា | ២% |

(យោងតាមទិន្នន័យរបស់ធនាគា អេស៊ីលីដា)

**ឃ.ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់**

ប្រជាពលរដ្ឋឃុំទំនប់រលកបានយកប្រាក់កំចីទៅប្រើប្រាស់ក្នុងៈ

-ពង្រីកមុខរបរ

-បង្កើតមុខរបរ

-ទិញទូក បោះទូក និងទិញឧបករណ៍នេសាទ

-ជួសជុលទូក និងជួសជុលឧបករណ៍នេសាទ

នៅក្នុងឃុំមានរោងសិប្បកម្មកែច្នៃ ផលនេសាទមានចំនួន ៤ កន្លែងមានកម្មករចំនួន ១៧០ នាក់ ប្រុស ចំនួន ៥០នាក់ និងស្រីចំនួន ១២០នាក់។ មានដេប៉ូប្រមូលទិញផលនេសាទមានចំនួន ១១ កន្លែង។

- មានរោងចក្របង់កក់ផលនេសាទ ១ កន្លែង មានកម្មករ ចំនួន ១២៧ នាក់ ។

**ង.ប្រភពជំនួយផ្សេងៗ :**

-ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និង កម្មវិធីវិនិយោគឃុំ សង្កាត់។

-សប្បុរសជនឧបត្ថម្ភ ជួសជុលរបងសាលារៀន ជួយជួសជុលផ្លូវ.......។

## ១.១.៥ ស្ថានភាពអប់រំ និងសិក្សាធិការ

ឃុំទំនប់រលកមានសាលាបឋមសិក្សា ១ កន្លែង ឈ្មោះសាលាបឋមសិក្សាទំនប់រលកថ្មី ដែលស្ថិតនៅក្នុង ភូមិ ៤ មាន ៦ អាគារ ស្មើនឹង ៣៧ បន្ទប់ មានទីចាត់ការ ០១កន្លែង និងបណ្ណាល័យ ០១បន្ទប់។ គិតជាមធ្យមពី សាលាឃុំទំនប់រលកទៅ សាលារៀនបឋមសិក្សាទំនប់រលកថ្មីមានចំងាយប្រមាណ ៧៥០ម៉ែត្រ រយៈពេលធ្វើដំណើរ ប្រមាណ ៤៥ នាទី។ ដែលមានសិស្សានុសិស្សសរុប ១១០៦នាក់ សិស្សស្រីមានចំនួន ៥៤៩នាក់។

**តារាងសាលា និងចំនួនសិស្ស**

| ប្រភេទសាលា | ចំនួនសាលានៅឆ្នាំ ២០០៨ | | | ចំនួនកុមារ/សិស្សនៅឆ្នាំ ២០០៨ | | | អត្រាមិនចូលរៀន |
|---|---|---|---|---|---|---|---|
| | សាលា | បន្ទប់ | ថ្នាក់ | កុមារសរុប | សិស្សសរុប | សិស្សស្រី | |
| ថ្នាក់មត្តេយសិក្សា | ១ | ២ | ២ | ៣១០ | ៨២ | - | ៧៤% |
| ថ្នាក់បឋមសិក្សា | ១ | ៣០ | ៣២ | ១១៨១ | ១១០៦ | ៥៤៩ | ៦ |
| ថ្នាក់អនុវិទ្យាល័យ | ១ | ៥ | ៨ | ៧១១ | ៦៥៨ | ៣៣៤ | ៧ |
| ថ្នាក់វិទ្យាល័យ | ០ | ០ | ០ | ៧៨១ | ៦៣១ | - | ១៥ |

( ប្រភព: ឯកសាពតិមានស្ថានភាពឃុំ ឆ្នាំ២០០៩)

-គ្រូមត្តេយ្យមានចំនួនសរុប ២នាក់ ( ស្រី២នាក់)

-គ្រូបង្រៀនថ្នាក់បឋមមានចំនួនសរុប ៣២នាក់ ស្រី១១នាក់

-គ្រូអនុវិទ្យាល័យ សរុប ១៦នាក់ ស្រី៤នាក់

-គ្រូសរុបមានចំនួន ៥០នាក់ ក្នុងនោះមានស្រី ១៧នាក់។

-សិស្សានុសិស្សសរុប មានចំនួន ១៨៤៦នាក់ ស្រី ៩២០នាក់






**ស្ថានភាពកុមារមិនបានចូលរៀនកំរិតបឋមសិក្សា**

| បរិយាយ | ចំនួន | | អត្រា% |
|---|---|---|---|
| | សរុប | ស្រី | |
| កុមារអាយុ៦ឆ្នាំ មិនបានរៀន | ៤៤ | - | ១៦.៤២% |
| កុមារអាយុ៦-១១ឆ្នាំ មិនបានរៀន | ៧៥ | ២ | ៦.៣៥% |

**អត្រាអក្ខរៈកម្ម**

| បរិយាយ | ចំនួន | | អត្រា% |
|---|---|---|---|
| | សរុប | ស្រី | |
| អ្នកមិនចេះអក្សរអាយុពី ១៥-៦០ឆ្នាំ | ១០៩៩ | ៥៩៩ | ១៦.៨២% |

## ១.១.៦ ស្ថានភាពសុខាភិបាល

### ១.១.៦.១ ផ្នែកសុខាភិបាល

ឃុំទំនប់រលកពុំមានមណ្ឌលសុខភាពទេ ដូចច្នេះប្រជាពលរដ្ឋត្រូវទៅព្យាបាលជំងឺនៅមណ្ឌលសុខភាពស្រុកដែលស្ថិតនៅក្នុងភូមិ៣ឃុំអូរត្រេះ គិតជាមធ្យមពីឃុំទំនប់រលកទៅមណ្ឌលសុខភាពមានចំងាយប្រមាណ ១៥00 ម៉ែត្រ ត្រូវប្រើរយៈពេល១៥នាទី ។ ប្រសិនបើមានអ្នកជំងឺធ្ងន់ត្រូវបញ្ជូនទៅមន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ គិតជាមធ្យមមានចំងាយ ២៨គីឡូម៉ែត្រ។

កុមារនៅឃុំទំនប់រលក បានចាក់ថ្នាំបង្ការ ១00% ។ ( ឯកសារមណ្ឌលសុខភាព២00៩ )

### ១.១.៦.២ ការផ្គត់ផ្គង់ទឹកស្អាត

ឃុំទំនប់រលកមានបណ្តាញទឹកស្អាតសំរាប់ប្រើប្រាស់ ១ កន្លែង និងអាងសំរាប់ស្តុបទឹក ១ កន្លែង ស្ថិតនៅក្នុងភូមិ ១ ចំណែកប្រភពទឹកយកមកពីព្រែករលួស ឃុំទំនប់រលកតភ្ជាប់ជាមួយឃុំអូរត្រេះ។ តំលៃទឹកក្នុង ១ ម៉ែត្រគីប ស្មើនឹង ៣000 រៀល តំលៃទឹក ១ ធុងសាំងស្មើ ២000រៀល ។ប្រជាពលរដ្ឋក្នុងឃុំនៅមានទឹកប្រើប្រាស់ដូចជា : ស្រះ អណ្តូងជីកដោយដៃ អណ្តូងលូ និងអណ្តូងស្នប់ផងដែរនៅរដូវវស្សា ប្រជាពលរដ្ឋប្រើប្រាស់ទឹកភ្លៀង ។

**តារាងប្រភពទឹក ស្រះ អណ្តូងជីកដោយដៃ អណ្តូងលូ និងអណ្តូងស្នប់**

| ល.រ | ប្រភពទឹកស្អាត | ចំនួនប្រភពទឹក | | | សំគាល់ |
|---|---|---|---|---|---|
| | | សរុប | ប្រើបាន | ខូចខាត | |
| ១ | អណ្តូងស្នប់ | ៦៩ | ៣៣ | ៣៦ | ខូចត្រូវជួសជុលឡើងវិញ |
| ២ | អណ្តូងលូ | ៩៣ | ៤៣ | ៥០ | ខូចត្រូវស្តារឡើងវិញ |
| ៣ | អណ្តូងដៃមិនដាក់លូ | ៤៨ | ៣៤ | ១៤ | រាក់ប្រើលែងកើត |
| ៤ | ស្រះទឹក | ៥ | ៥ | 0 | ទឹកល្អសំរាប់ប្រើបាស់ |
| ៥ | ប្រភពដែលបានឆ្លងកាត់ធ្វើឱ្យទឹកស្អាត | ១៤០៤ | ១៤០៤ | 0 | ប្រើប្រាស់ពេញមួយឆ្នាំ |

ប្រភព: របាយការណ៍ ស្តីពីស្ថានភាពឃុំទំនប់រលកឆ្នាំ ២០០៨

## ១.២ ស្ថានភាពភូមិសាស្ត្រ

### ១.២.១ ទីតាំងភូមិសាស្ត្រ

ឃុំទំនប់រលកមានសណ្ឋានដីជាវាលទំនាប ខ្ពង់រាប និងស្ថិតនៅចន្លោះពី :

- 1178000 mN ទៅ 1189000 mN នៃរយៈបណ្តោយ ខាងជើង
- 348000 mE ទៅ 362000 mE នៃរយៈទទឹងខាងកើត

ឃុំនេះមានរយៈកំពស់:

- ពី 0-៤៧ ម៉ែត្រ វាលទំនាប (ព្រៃលិចទឹក)
- ពី ៤៧-៦៥ ម៉ែត្រ ខ្ពង់រាប
- ពី ៦៥-២១៦ ម៉ែត្រ ភ្នំ និងជាប្រភេទ ដីល្បាយខ្សាច់ ល្បាយភក់ ដីគ្រួសក្រហម ។

ប្រភពទឹកក្នុងឃុំទំនប់រលក មានព្រែកអូរតាមភូមិ ទឹកសមុទ្រ ស្រះ អណ្តូងជីកដៃ អណ្តូងលូ និង អណ្តូងស្នប់ ។



## ១.២.២ អាកាសធាតុ

អាកាសធាតុ ឃុំទំនប់រលកក៏ដូចជាខេត្តព្រះសីហនុដែរ បានទទួលឥទ្ធិពលនៃខ្យល់ម៉ូសុងត្រូពិច ដែលបានបែងចែកពីររដូវ គឺរដូវប្រាំង និង រដូវវស្សា ។

-រដូវប្រាំងក៏រិតសីតុណ្ហភាព អតិបរិមាពី ៣០ អង្សាសេ ទៅ ៤០ អង្សាសេ

-រដូវវស្សាក៏រិតសីតុណ្ហភាព អប្បរមា ពី ១៩អង្សាសេ ទៅ២១ អង្សាសេ

-រដូវវស្សាចាប់ពីពាក់កណ្តាលខែមេសា ដល់ខែតុលាក៏រិតទឹកភ្លៀង បរិមាមធ្យម ៣៨០.១៩មម ។

**កំពស់ទឹក**

-ខែមេសាកំពស់ទឹកសមុទ្រ អប្បរមា ២ម

-ទឹកសន្សើមជាតិប្រៃ

**តួរលេខអាកាសធាតុដែលពិនិត្យឃើញ នៅស្ថានីយ៍ឧតុនិយម ខេត្តព្រះសីហនុ ឆ្នាំ២០០៩**

| ខែ | កំពស់ទឹកភ្លៀង | សីតុណ្ហភាពគិតជាអង្សាសេ | | សំណើម | ទិស.ល្បឿនខ្យល់ | | |
|---|---|---|---|---|---|---|---|
| | ម.ម | អតិបរមា | អប្បរមា | ស្ងួត | សើម | មធ្យម | m/s |
| | | មធ្យម | មធ្យម | មធ្យម | មធ្យម | ភាគរយ | |
| មករា | 2.4 | 31.5 | 20.0 | 27.5 | 24.5 | 90.5 | N-10 |
| កុម្ភៈ | 6.8 | 32.5 | 23.5 | 27.3 | 23.5 | 84.6 | NE-05 |
| មិនា | 113.3 | 33.5 | 23.5 | 27.7 | 24.9 | 90.7 | SE-06 |
| មេសា | 127.4 | 33.5 | 23.5 | 28.5 | 24.5 | 87.0 | NW-07 |
| ឧសភា | 353.2 | 33.5 | 24.0 | 27.6 | 25.3 | 83.7 | NE-07 |
| មិថុនា | 141.5 | 32.5 | 23.5 | 27.8 | 25.3 | 83.2 | NW-13.0 |
| កក្កដា | 379.1 | 32.0 | 22.5 | 26.9 | 24.5 | 86.0 | NW-17.0 |
| សីហា | 220.8 | 32.5 | 23.5 | 27.7 | 24.6 | 83.1 | NW-09 |
| កញ្ញា | 713.9 | 32.0 | 23.0 | 26.1 | 24.0 | 89.1 | NW-10 |
| តុលា | 215.7 | 30.4 | 24.7 | 27.0 | 25.1 | 86.1 | NW-14 |
| វិច្ឆិកា | 14.4 | 31.8 | 25.4 | 27.8 | 25.3 | 80.2 | NE-10 |
| ធ្នូ | 52.7 | 31.1 | 23.0 | 26.9 | 24.1 | 79.9 | NE-09 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| សរុប | 2342.4 | 372.3 | 293.2 | 328.8 | 299.6 | 1024.1 | |
| មធ្យម | | 31.2 | 24.4 | 27.4 | 25.0 | 85.3 | |

ទឹកភ្លៀងឆ្នាំ ១៩៩៧ ដល់ ឆ្នាំ ២០០៨

| ឆ្នាំ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1997 | 0.0 | 3.4 | 136.0 | 88.8 | 144.1 | 59.5 | 597.4 | 765.3 | 295.0 | 326.1 | 167.3 | 100.4 | 2683.3 |
| 1998 | 35.6 | 20.0 | 18.4 | 34.6 | 321.9 | 726.6 | 488.9 | 553.6 | 629.5 | 283.5 | 132.8 | 23.0 | 3268.4 |
| 1999 | 68.1 | 121.2 | 145.9 | 275.2 | 383.5 | 469.1 | 766.9 | 379.2 | 518.7 | 426.6 | 225.3 | 50.7 | 3830.4 |
| 200 | 70.8 | 82.3 | 66.6 | 289.6 | 298.5 | 538.3 | 434.0 | 957.7 | 111.4 | 506.2 | 57.7 | 25.5 | 3438.6 |
| 2001 | 115.6 | 62.2 | 165.9 | 156.1 | 430.7 | 589.1 | 294.1 | 847.0 | 308.1 | 370.2 | 32.5 | 26.0 | 3397.5 |
| 2002 | 7.4 | 6.8 | 84.9 | 183.2 | 403.9 | 431.0 | 256.2 | 930.9 | 518.4 | 70.5 | 190.3 | 89.6 | 3173.1 |
| 2003 | 0.0 | 4.4 | 244.7 | 71.1 | 327.9 | 432.4 | 472.9 | 477.1 | 390.2 | 383.5 | 23.6 | 3.6 | 2831.4 |
| 2004 | 39.5 | 25.4 | 53.0 | 192.4 | 424.5 | 546.5 | 849.0 | 733.2 | 282.5 | 143.1 | 71.5 | 0.0 | 3360.6 |
| 2005 | 51.1 | 0.4 | 48.4 | 170.6 | 322.5 | 454.3 | 705.1 | 366.3 | 383.2 | 258.7 | 68.9 | 67.6 | 2897.2 |
| 2006 | 121.6 | 127.6 | 79.9 | 197.0 | 447.0 | 562.4 | 927.3 | 611.4 | 519.3 | 349.8 | 92.0 | 29.5 | 4064.8 |
| 2007 | 2.5 | 3.9 | 134.7 | 227.1 | 270.4 | 289.1 | 695.2 | 449.3 | 820.1 | 316.6 | 125.6 | 30.2 | 3364.7 |
| 2008 | 0.0 | 33.2 | 145.2 | 189.4 | 396.2 | 482.2 | 335.3 | 435.4 | 484.6 | 370.7 | 87.8 | 0.1 | 2960.1 |
| Max | 121.6 | 127.6 | 244.7 | 289.6 | 447.0 | 726.6 | 927.3 | 957.7 | 820.1 | 506.2 | 225.3 | 100.4 | 4064.8 |
| Aver | 46.6 | 41.6 | 107.1 | 171.4 | 343.2 | 463.5 | 589.7 | 642.8 | 434.2 | 312.3 | 108.0 | 40.6 | 3300.9 |
| Min | 0.0 | 0.4 | 18.4 | 34.6 | 144.1 | 59.5 | 256.2 | 366.3 | 111.4 | 70.5 | 23.6 | 0.0 | 2683.3 |

### ១.២.៣ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន

ប្រពន្ធ័គមនាគមន៏ក្នុងឃុំទំនប់រលកអាចឱ្យប្រជាពលរដ្ឋធ្វើចរាចរណ៏ទំនាក់ទំនងក្នុងឃុំបានល្អ ។ ប៉ុន្តែមិនទាន់គ្រប់គ្រាន់ទេប្រពន្ធ័គមនាគមន៏របស់ឃុំមាន : ផ្លូវគោ ផ្លូវដែក ផ្លូវទឹក ។

**ក.ផ្លូវគោក**

- ផ្លូវក្រាលកៅស៊ូមានចំនួនៈ៣ ខ្សែ

-ខ្សែទី១ៈមានប្រវែងប្រមាណ៨000ម៉ែត្រ ចេញពីព្រំប្រទល់ឃុំអូរគ្រេះទៅទល់នឹងព្រែកក្រពើពងព្រំប្រទល់ស្រុកព្រៃនប់

-ខ្សែទី ២ៈ មានប្រវែងប្រមាណ ២២00 ម៉ែត្រ ចេញពីមុខផ្សារស្ទឹងហាវ ទៅទល់នឹងអូរទូកឃុំកំពេញ ។

-ខ្សែទី ៣: មានប្រវែងប្រមាណ ១៣០០ ម៉ែត្រ ចេញពីមុខផ្សារស្ទឹងហាវ ទៅទល់នឹងអូរទូកឃុំកំពេញ



- ផ្លូវក្រាលបេតុង

- ផ្លូវក្រាលបេតុងមានចំនួន ១ ខ្សែមានប្រវែងប្រមាណ ៩៣០ ម៉ែត្រចេញពីរុក្ខវិថីសម្តេចហ៊ុនសែន ទៅទល់នឹងភូមិ១ឃុំទំនប់រលក។



- ផ្លូវក្រាលគ្រួសក្រហមមានចំនួន ១៨ ខ្សែ

- ខ្សែទី ១ :មានប្រវែងប្រមាណ ៩៧៥ ម៉ែត្រ ចេញពីភូមិ៤ទៅទល់នឹងសមុទ្រ

- ខ្សែទី ២ :មានប្រវែងប្រមាណ ៦១០ ម៉ែត្រ ចេញពីផ្លូវក្រាលកៅស៊ូទៅទល់នឹងសមុទ្រ

- ខ្សែទី ៣ : មានប្រវែងប្រមាណ ៩៨០ ម៉ែត្រ ចេញពីវុក្ខវិថីសម្តេចហ៊ុនសែនទៅទល់នឹងសមុទ្រ

- ខ្សែទី ៤ :មានប្រវែងប្រមាណ ១១៣០ ម៉ែត្រ ចេញពី វុក្ខវិថីសម្តេចហ៊ុនសែន ទៅទល់នឹងកូនព្រែកភូមិ១

- ខ្សែទី ៥ : មានប្រវែងប្រមាណ ៥៨០ ម៉ែត្រ ចេញពីផ្លូវក្រាលកៅស៊ូទៅទល់នឹងព្រែកភូមិ ១

- ខ្សែទី ៦ :មានប្រវែងប្រមាណ ៩១៥ ម៉ែត្រ ចេញពីវុក្ខវិថីសម្តេចហ៊ុនសែនទៅទល់នឹងព្រែកភូមិ១

- ខ្សែទី ៧ :មានប្រវែងប្រមាណ ៣៨៥ ម៉ែត្រ ចេញពីភូមិ ៣ទៅទល់នឹងកូនព្រែក១

- ខ្សែទី ៨ :មានប្រវែងប្រមាណ ៣៧០ ម៉ែត្រ ចេញពីភូមិ ៣ទៅទល់កូនព្រែក១

- ខ្សែទី ៩ : មានប្រវែងប្រមាណ ៦៨០ ម៉ែត្រ ចេញពីផ្លូវក្រាលកៅស៊ូទៅទល់នឹងកូនព្រែក១

- ខ្សែទី ១០ : មានប្រវែងប្រមាណ ៣១០ ម៉ែត្រ ចេញពីទំនប់ទឹកទៅទល់នឹងកូនព្រែកភូមិ ១

- ខ្សែទី ១១ : មានប្រវែងប្រមាណ ៣៣០ ម៉ែត្រ ចេញពីវុក្ខវិថីសម្តេចហ៊ុនសែន ទៅទល់នឹងទំនប់ទឹកសាប

- ខ្សែទី ១២ : មានប្រវែងប្រមាណ ៣១៥ ម៉ែត្រ ចេញពីផ្លូវក្រាលកៅស៊ូទៅទល់ចេញពីវុក្ខវិថី សម្តេចហ៊ុនសែន ទៅទល់នឹងភូមិ៤

- ខ្សែទី ១៣ : មានប្រវែងប្រមាណ ៦៨០ ម៉ែត្រ ចេញពីទំនប់ទឹកទៅទល់នឹងសមុទ្រ

- ខ្សែទី ១៤ : មានប្រវែងប្រមាណ ៦១០ ម៉ែត្រចេញពីភូមិ៤ ទៅទល់នឹងសាលាឃុំទំនប់រលក

- ខ្សែទី ១៥ : មានប្រវែងប្រមាណ ៦០០ ម៉ែត្រ ចេញពីភូមិ២ទៅទល់នឹងសមុទ្រ

- ខ្សែទី ១៦ : មានប្រវែងប្រមាណ ៦១៥ ម៉ែត្រ ចេញពីភូមិ១ ទៅទល់នឹងសមុទ្រ

- ខ្សែទី ១៧ : មានប្រវែងប្រមាណ ៣១៥ ម៉ែត្រ ចេញពីផ្លូវក្រាលកៅស៊ូទៅទល់នឹងសមុទ្រ

- ខ្សែទី ១៨ : មានប្រវែងប្រមាណ ១២០០ ម៉ែត្រ ចេញពីរុក្ខវិថីសម្តេចហ៊ុនសែន ទៅទល់នឹងផ្លូវសម្តេចសង្ឃទេពវង្ស។



**ខ.ផ្លូវដែក** : មានចំនួនមួយខ្សែចាប់ពីព្រំប្រទល់ឃុំអូរត្រេះ ទៅទល់នឹងព្រែកព្រំប្រទល់ស្រុកព្រៃនប់មានប្រវែងប្រមាណ ៦៥០០ម។



**គ.ផ្លូវទឹក**

ឃុំទំនប់រលកជាប់ និងសមុទ្រដែលមានជំរៅទឹកជ្រៅល្មមអំណោយផលដល់ការកសាងកំពង់ផែដឹកជញ្ជូន និងកំពង់ផែទិញផលនេសាទតាមសមុទ្រ ។



មានព្រែកចំនួន ២ខ្សែ

- ខ្សែទី ១ : មាន ព្រែកថ្មរ៉ុង ស្ពានព្រែកថ្មមានប្រវែងប្រមាណ ៧៥០-៨០០..ម៉ែត្រ ចេញពីសមុទ្រ ទៅទល់និងព្រំ ប្រទល់ស្រុកព្រៃនប់ ។

- ខ្សែទី ២ :មានព្រែករលួសមានប្រវែងប្រមាណ ៨០០-៨៦០.ម៉ែត្រចេញពីទំនប់សម្តេច ហ៊ុន សែន ទៅទល់និង ព្រំប្រទល់ខេត្តព្រះសីហនុ ។



(យោងតាមការសាកសួររបស់ក្រុមប្រឹក្សាឃុំ)

## ១.៣ ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

ដីលំនៅដ្ឋាននៅឃុំទំនប់រលកចែកចេញជា ៣ ប្រភេទ ដែលមានស្ថានភាពខុសគ្នា

១.ដីលំនៅដ្ឋានឆ្នេរសមុទ្រជើងភ្នំ និងព្រៃកភាគច្រើនប្រជាពលរដ្ឋរស់នៅរាយប៉ាយគ្នានៅតាមមាត់ព្រែក ឆ្នេរសមុទ្រ និងជើងភ្នំដែលកកើតនៅឆ្នាំ ១៩៨៤ កន្លែងខ្លះទួល កន្លែងខ្លះជាប់មាត់សមុទ្រ ដីលំនៅដ្ឋានទាំងអស់មិនដូចគ្នាទេ ដោយសារគ្រួសារខ្លះមានដីធំទូលាយជាមធ្យម ១០ម គុណ ៣០ម ដីលំនៅដ្ឋានភាគច្រើនធ្វើហើយ ដីដែលសាងសង់លំនៅដ្ឋានមួយចំនួនពុំសមស្របច្បាប់ គឺជាដីកម្មសិទ្ធិរបស់រដ្ឋ គឺគាត់រស់តាមមាត់ព្រែក និងមាត់ សមុទ្រ រីឯលំនៅដ្ឋានភាគច្រើនធ្វើអំពីឈើអារប្រកសង្កសី ជញ្ជាំងក្តារ ខ្លះជញ្ជាំងសង្កសីសង់ជាប់នឹងដី ខ្លះសង់ខ្ពស់ពីដីតាមធនធានគ្រួសារនីមួយៗនៅក្នុងភូមិសង្កេតឃើញមានដំណាំហូបផ្លែមួយចំនួនដូចជា ដូង ស្វាយ ខ្នុរ ល្ហុង និងដំណាំរួមផ្សំនៅមុខ រឺក្រោយផ្ទះ។

### ១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី

ការប្រើប្រាស់ដីនៅក្នុងឃុំទំនប់រលកចែកចេញជាៈ

-ដីសាមញ្ញមានចំនួន ៦ ប្រភេទ

-ដីលំអិតមានចំនួន ១៦ ប្រភេទ

តារាងចំណាត់ថ្នាក់ប្រើប្រាស់ដីសាមញ្ញបច្ចុប្បន្ន

| កូដ | ចំណាត់ថ្នាក់ប្រើប្រាស់ដី (តាមបច្ចេកទេស) | ចំណាត់ថ្នាក់ប្រើប្រាស់ដី (តាមមូលដ្ឋាន) | ក្រឡាផ្ទៃ | |
|---|---|---|---|---|
| | | | គម.ក្រឡា | ហិចតា |
| | លំនៅដ្ឋាន | លំនៅដ្ឋាន | 1.554316 | 155.4316 |
| | កសិកម្ម | ចំការ | 8.762908 | 876.2908 |
| | ព្រៃកោងកាង | ដីកោងកាង | 2.027714 | 202.7714 |
| | វាលស្មៅ វាលស្បូវ | វាលស្មៅ វាលស្បូវ | 38.715 | 3874.15 |
| | ប្រភពទឹក | អាងទឹក | 0.131685 | 13.1685 |
| | ដីដែលគ្មានរុក្ខជាតិដុះគ្របដណ្តប់ | ដីឃ្សាច់ឆាយ | 0.033311 | 3.3311 |

| សរុប | 51.25143 | 5125.143 |
|---|---|---|




តារាង ចំណាត់ប្រើប្រាស់ដីលំអិតបច្ចុប្បន្ន

| កូដ | ចំណាត់ថ្នាក់ប្រើប្រាស់ដី (តាមបច្ចេកទេស) | ចំណាត់ថ្នាក់ប្រើប្រាស់ដី (តាមមូលដ្ឋាន) | ក្រឡាផ្ទៃ | |
|---|---|---|---|---|
| | | | គម.ក្រឡា | ហិចតា |
| 1100 | ដីលំនៅដ្ឋានទីប្រជុំជន | ដីលំនៅដ្ឋានទីប្រជុំជន | 0.671588 | 67.1588 |
| 1200 | ដីលំនៅដ្ឋានភូមិ | ដីភូមិ | 0.711839 | 71.1839 |
| 1300 | ហេដ្ឋារចនាសម្ព័ន្ធ | ដីផ្លូវ | 0.165263 | 16.5263 |
| 1320 | ដីវាលកប់ខ្មោច | ដីបញ្ចុះសព | 0.005626 | 0.5626 |
| 2111 | ដីស្រែជាមួយភូមិ | ដីស្រែជាមួយភូមិ | 0.028913 | 2.8913 |
| 2200 | ចំការដំណាំ | ដីដាំដំណាំ | 2.278 | 227.8 |
| 2310 | ចំការឈើហូបផ្លែ | ចំការឈើហូបផ្លែ | 0.457318 | 45.7318 |

| | | | | |
|---|---|---|---|---|
| 2324 | ចំការព្រៃដាំ | ចំការព្រៃដាំ | 5.998677 | 599.8677 |
| 3600 | ព្រៃកោងកាង | ព្រៃលិចទឹក | 1.083049 | 108.3049 |
| 3610 | ព្រៃកោងកាងស្តើង | ព្រៃលិចទឹកស្តើង | 0.944665 | 94.4665 |
| 4100 | វាលស្មៅ | វាលស្មៅ | 24.902648 | 2490.2648 |
| 4110 | ចំការបោះបង់ដុះស្មៅ | ចំការបោះបង់ដុះស្មៅ | 1.182738 | 118.2738 |
| 4500 | ព្រៃគម្ពោធ | ព្រៃគម្ពោធ | 12.65611 | 1265.611 |
| 5120 | អាង ឬ ទំនប់ | អាង ឬទំនប់ | 0.040196 | 4.0196 |
| 5220 | សមុទ្រ | សមុទ្រ | 0.091489 | 9.1489 |
| 6200 | ដីខ្សាច់ | ដីខ្សាច់ | 0.033311 | 3.3311 |
| | | | | |



## ១.៣.២ ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដី

ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដីនៅក្នុងឃុំទំនប់រលកក្រៅពីដីលំនៅដ្ឋាន ដីចំការ ដំណាំចំការឈើហូបផ្លែ ដែលជាកម្មសិទ្ធិរបស់ឯកជន ឯដីសាធារណៈរបស់រដ្ឋ។

- មានដី គំរបព្រៃបៃតង
- ព្រៃកោងកាង
- សមុទ្រ
- ខ្សាច់

| ល.រ | ចំណាត់ថ្នាក់នៃការគ្រប់គ្រង និងកាន់កាប់ដី | | ក្រឡាផ្ទៃ( ហិចតា) |
|---|---|---|---|
| | តាមច្បាប់អនុញ្ញាត និងតួនាទី | តាមចំណាត់ថ្នាក់ដីរដ្ឋ ឯកជន | |
| ១ | ដីគំរបព្រៃបៃតង | ដីសាធារណៈរបស់រដ្ឋ | ១០៥០( យោងតាមទិន្នន័យឃុំ) |
| ២ | ដីព្រៃកោងកាង | ដីសាធារណៈរបស់រដ្ឋ | ១០៨.៣០៤៩ |
| ៣ | សមុទ្រ | ដីសាធារណៈរបស់រដ្ឋ | ៩.១៤៨៩ |
| ៤ | ខ្សាច់ | ដីសាធារណៈរបស់រដ្ឋ | ៣.៣៣១១ |

## ១.៣.៣ ផលិតកម្មកសិកម្ម

### ១.៣.៣.១ ផលិកម្មដំណាំស្បៀង

**ឃុំទំនប់រលកពុំមានដំណាំផលិកម្មស្បៀងទេ។**

## ១.៣.៤ ធនធានធម្មជាតិ

កាលពីអតីតកាល ភូមិ១ក្នុងឃុំទំនប់រលក សំបូរទៅដោយធនធានធម្មជាតិជាច្រើនដូចជាៈ

- ដីភ្នំ និងដីព្រៃសំបូរទៅដោយឈើល្អ មានសត្វព្រៃគ្រប់ប្រភេទ ក្នុងស្រែមានមច្ឆាជាតិ និងព្រៃលិចទឹកសំបូរទៅដោយជីវចំរុះទាំងឡាយ ។

ក្នុងភូមិមានប្រជាពលរដ្ឋរស់នៅតិចតួច ជីវភាពសំបូរធនធាន។ ប៉ុន្តែក្រោយសង្គ្រាមក្នុងស្រុក ត្រូវបានបញ្ចប់ការវិលត្រឡប់មករស់នៅកស្រុកភូមិវិញ ព្រមទាំងមានអ្នកចំណូលស្រុកផងដែរ ។

បច្ចុប្បន្នប្រជាពលរដ្ឋក្នុងភូមិចេះតែកើនឡើង តំរូវការខាងជីវភាពចេះតែកើនឡើងដែរ ។ដោយពុំមានការគ្រប់គ្រងនិងប្រើប្រាស់ធនធានអោយបានច្បាស់លាស់ជាហេតុធ្វើអោយប្រជាពលរដ្ឋមួយចំនួននាំគ្នាកាប់ទន្ទ្រានរានយកដីបំផ្លិចបំផ្លាញធនធានធម្មជាតិក្នុងឃុំទំនប់រលកស្ទើរតែបាត់បង់ទាំងស្រុង ។

ដោយមើលឃើញនូវការប្រើប្រាស់ដីធ្លីពុំសមស្រប និងការបាត់បង់នូវធនធានធម្មជាតិយ៉ាងឆាប់រហ័ស ដូចនេះរាជរដ្ឋាភិបាលបានជំរុញឱ្យមានការបង្កើតឡើងនូវក្រុមការងារសំរបសំរួលការរៀបចំធ្វើផែនការប្រើប្រាស់ដីធ្លីដោយ

មានការចូលរួមក្នុងគោលបំណងគឺជួយប្រជាពលរដ្ឋក្នុងឃុំឱ្យចេះអភិរក្សធនធានធម្មជាតិឱ្យមានលំនឹង ឡើងវិញអោយចេះប្រើប្រាស់ដីធ្លីព្រមទាំងធនធានធម្មជាតិឱ្យបានសមស្របតាមលក្ខណៈបច្ចេកទេស និងមាន និរន្តរភាពទៅអនាគត។

**១.៣.៤.១ <u>ធនធានព្រៃឈើ</u>**

ឃុំទំនប់រលកមានផ្ទៃដីព្រៃឈើ ចំនួនប្រមាណ ១០៥០ ហិចតា លាតសន្ធឹងតាមផ្លូវដែក ទៅទល់នឹងឃុំ សំរ៉ុង ស្រុកព្រៃនប់ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ នឹងមានប្រភេទឈើដូចជា:

- នាងដែង ឈើទាល គគីរ ភ្នង ក្រៅពីព្រៃឈើនៅមានប្រភេទសត្វព្រៃដូចជា : ស្វា ជ្រូកព្រៃ ទន្សាយ ពស់ ត្រកួត សំប៉ូច ស្កា ទោច...។



**ព្រៃលិចទឹក**

ឃុំទំនប់រលកមានផ្ទៃដីព្រៃកោងកាង ចំនួនប្រមាណ ២០២.៧៧១៤ ហិចតា លាតសន្ធឹងតាមបណ្ដោយឆ្នេរ និងព្រែកថ្មរ៉ុង ដូចជា : កោងកាង ស្មែរ ប្រាសាក់ ក្បាញ ក្រញឹបក្រហម ឈើជ័រ ប៉ើស តាប៉ុន ជំពូព្រែក អំពូរ អំពារ ចាក ត្រចៀកក្រាញ់ .........។



### ១.៣.៤.២ ធនធានជលផល

ប្រភេទធនធានជលមានៈ បង្គា ក្តាម ត្រី ខ្យង មឹក ត្រីស្លង់ ត្រីអាំកើយ ត្រីកាម៉ុងត្រីចាប ត្រីបបែល បង្កងកណ្តូប ។

ទិន្នន័យប្រចាំឆ្នាំ ( ប្រភព កសិកម្មស្រុក)

| ផលនេសាទ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|
| បង្គាស្រស់ចំរុះ | ៧.២៧៨ គ ក្រ | ៥.៩៤០ គ ក្រ | ១២៤.៣១០ គក្រ | ១១.២២០ គ ក្រ |
| មឹកស្រស់ | ៥.១៦០ គ ក្រ | ៥.២៦០ គ គ្រ | ១៦.២០០ គ ក្រ | ១៤.៣២១ គ ក្រ |
| ក្តាម | ៦.៩៨៩ គ ក្រ | ៧៣.៤៤០ គ ក្រ | ៣៤.៣០៥ គ ក្រ | ៤.១៥៩ គ ក្រ |
| បង្កងកណ្តូប | ៤៧៥ គ ក្រ | ២០០ គ ក្រ | ១.១៩៣ គ ក្រ | ២.៨៦១ គ ក្រ |
| ត្រីជី | ៣០.០០០ គ ក្រ | ៣៤.៦០០ គ ក្រ | ១៧៥.២៦៣ គ ក្រ | ១៧.៩៧៩ គ ក្រ |

**ផលកែឆ្នៃ**

| | | | | |
|---|---|---|---|---|
| សាច់ក្តាម | ២.៣០០ គ ក្រ | ៣០.៤០ គ ក្រ | ៨.៤៦៤ គ ក្រ | ២.១០៧ គ ក្រ |
| ក្តាមស្ងោរ | ១៥០ គ ក្រ | ១.០០០ គ ក្រ | ៣.២០០ គ ក្រ | ៣.៣០០ គ ក្រ |
| ត្រីចំហុយ | ៣.០០០ គ ក្រ | ២.៨៤០ គ ក្រ | ៥.៤៣០ គ ក្រ | ៤.៤០០ គ ក្រ |

ផលនេសាទដែលប្រមូលបាន ឃុំទំនប់រលក ផ្គត់ផ្គង់នៅក្នុងឃុំ ទីផ្សារស្ទឹងហាវ និង ក្រៅឃុំ ទីផ្សារខេត្ត ព្រះសីហនុ ភ្នំពេញ វៀតណាម ទីផ្សារទំនប់រលកទំនប់រលកចាស់ ។

ប្រជាពលរដ្ឋក្នុងឃុំភាគច្រើនប្រើឧបករណ៍នេសាទប្រភេទ ដូចជា:

-អួន អួស

-មង បង្គា

-មង ត្រី

-លប ក្តាម



### ១.៣.៥ ធនធានរ៉ែ

ប្រមូលប្រភពទិន្នន័យមិនបាន។

## ១.៤ ទីផ្សារ និងខ្សែចង្វាក់ផលិតផល

### ១.៤.១ ទីផ្សារនិងតម្លៃផលនេសាទ

| ល.រ | រាយមុខទំនិញ | ឯកត្តា | តំលៃឯកត្តា ( រៀល ) |
|---|---|---|---|
| ១ | បង្កងកណ្តូប | គ .ក្រ | ១០០.០០០ |
| ២ | ក្តាមថ្ម | គ ក្រ | ៣០.០០០ |
| ៣ | ត្រីប្លូធូ | គ ក្រ | ២.០០០ |
| ៤ | ត្រីចំរុះ | គ ក្រ | ៧.០០ |
| ៥ | ត្រីអាំងកើយ | ផ្លែ | ២០.០០០ |
| ៦ | ត្រីស្តូង | គ ក្រ | ២០.០០០ |

| | | | |
|---|---|---|---|
| ៧ | បង្គា | គ ក្រ | ១៨.000 |
| ៨ | ក្តាមថ្ម | គ ក្រ | ៣៥.000 |
| ៩ | ត្រី | គ ក្រ | ១៥.000 |
| ១០ | មឹក | គ ក្រ | ១៨.000 |
| ១១ | ក្តាមសេះ | គ ក្រ | ១៧.000 |
| ១២ | មឹក | គ ក្រ | ៨.000 |
| ១៣ | ត្រីតុកកែ | គ ក្រ | ៤0.000 |

### ១.៩.២ ខ្សែចង្វាក់ និងខ្សែចរាចរផលិតផល




### ១.៩.៣ ឱកាស និង ឧបសគ្គ

**ក. ឱកាស**

- មានផៃប្រមូលទិញផលនេសាទសមុទ្រ ។
- មានទីផ្សារសំរាប់លក់ចេញទាន់ពេលវេលា ។
- មានរោងចក្របង់កក 0១ កន្លែង នៅក្នុងឃុំ ។
-មានសហគមន៍នេសាទគ្រប់គ្រងធនធានជលផល ។
-មានការចូលរួមផ្សព្វផ្សាយ និង ទប់ស្កាត់បទល្មើសជលផលពី រដ្ឋបាលជលផល ។
-មានការជួយឧបត្ថម្ភពីសំណាក់អង្គការនានាក្នុងការថែរក្សាធនធានជលផល ។

**ខ. ឧបសគ្គ**

- មានតំលៃទាប មិនមានតុល្យភាព នឹងទំនិញទីផ្សារ ។
- ការនេសាទរបស់ប្រជាពលរដ្ឋភាគច្រើនប្រើប្រាស់ឧបករណ៍គ្រឿងយន្ត រីឯប្រេងឥន្ទនៈមានតម្លៃខ្ពស់ ផលដែលត្រូវលក់មានតំលៃទាប ។

-ប្រជាពលរដ្ឋមិនទាន់យល់ច្បាស់ពីការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់លើធនធានជលផល ដូចជា : ការប្រើប្រាស់ អាគុយឆក់ , មងហោះ ។

-កំណើនប្រជាពលរដ្ឋធ្វើឱ្យមានសំពាធកាន់តែខ្លាំទៅលើធនធានជលផល ។

-មានការកាប់ព្រៃកោងកាងតាមមាត់ព្រែករានយកដីធ្វេរធ្វើលំនៅដ្ឋាន ។

- ជំរៅទឹករាក់ក្រោម ២០ ម៉ែត្រ មិនអនុញ្ញាតអោយប្រើមងអួស ។

# ជំពូក២

# ការវិភាគពី តំរូវការសំរាប់អនាគត

## ២.១ តំបន់សើប

ឃុំទំនប់រលកមានតំបន់សេដ្ឋកិច្ចពិសេស ចំនួន ១ កន្លែង ស្ថិតនៅក្នុងភូមិ១។ តំបន់សេដ្ឋកិច្ចពិសេសរបស់ក្រុមហ៊ុនអ៊ែតរូតនីហារណ៍អាហារណ៍ ដែលមានផ្ទៃដីចំនួន ១៩៨ ហិកតា យោងតាមអនុក្រឹត្យ............................. ................................. ។

- តំបន់សេដ្ឋកិច្ចពិសេសខាងលើនេះ ក្រុមហ៊ុនមិនទាន់បានដំណើរការនៅឡើយទេ។

-ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស មានផលប៉ះពាល់ និងបាត់បង់ដីចំការ ដីគំរបព្រៃបៃតង ។ ប៉ុន្តែដោយការវិភាគដោយយកចិត្តទុកដាក់ពីក្រសួងពាក់ព័ន្ធបានឯកភាពគ្នាពីផលប៉ះពាល់ និងការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសនេះ មានផលប្រយោជន៍ជាងការរក្សាទុកធនធានទាំងនោះ ។ ដោយឃុំទំនប់រលកពឹងផ្អែកទៅលើសក្តានុពលទៅលើការនេសាទសមុទ្រ និងឧស្សាហកម្ម។

**ធនធានព្រៃលិចទឹក**

ចំពោះធនធានជលផល គឺជាធនធានមួយដែលមានសក្តានុពលយ៉ាងខ្ពស់ ក្រៅពីការផ្តល់ជាអាហារ គឺជាប្រភពចំណូលមួយយ៉ាងសំខាន់សំរាប់ ប្រជាសហគមន៍ ក៏ដូចជាសេដ្ឋកិច្ចជាតិ តែបច្ចុប្បន្ន ការប្រើប្រាស់ធនធានមានការប៉ះពាល់ខ្លាំង គឺធ្វើអោយធនធានទទួលរងនូវគ្រោះថ្នាក់យ៉ាងខ្លាំង ដូចជា ការកាប់អុសព្រៃលិចទឹក ការធ្វើអាជីវកម្ម កាប់រាតយកដីព្រៃលិចទឹកយកដីលក់ និង ធ្វើជាកម្មសិទ្ធិ ការដុតព្រៃលិចទឹកយកសត្វ ការប្រើឧបករណ៍នេសាទខុសច្បាប់ធ្វើអោយធនធានធម្មជាតិក្នុងឃុំមានការថយចុះជាលំដាប់។ ការបង្កើតសហគមន៍ គឺជាឱកាសក្នុងការការពារធនធានធម្មជាតិ និងការបង្កើនប្រាក់ចំណូល។

- គោលដៅការពារបរិស្ថានធនធានធម្មជាតិមាន ១០៨.៣០៤៩ ហិចតា
- ព្រៃកោងកាងស្តើង ៩៤.៤៦៦៥ ហិចតា



## ២.២ ការប្រឈម/ឧបសគ្គ

### ២.២.១ ការប្រឈមដោយធម្មជាតិ

ទំហំគ្រួសារបង្ហាញពីចំនួនសមាជិកក្នុងគ្រួសារ ចំនួនជាមធ្យមនៃគ្រួសារគឺមាន ៥នាក់នាពេលបច្ចុប្បន្ន ។ យោងលើស្ថានភាពឃុំឆ្នាំ ២០០៩ បានបង្ហាញថា ក្នុងឆ្នាំ ២០០៨ ចំនួនគ្រួសារ ក្នុងឃុំទំនប់រលក មានការថយចុះដោយសារការធ្វើចំណាកស្រុក( ភាពគ្មានដីធ្លី គ្មានការងារ) ។ ភាពមិនប្រែប្រួលនៃទំហំគ្រួសារនៅតែមានកំរិតខ្ពស់ បង្ហាញពីភាពចាំបាច់ត្រូវបន្តអនុវត្តន៍កម្មវិធីពន្យាកំណើត ដើម្បីគ្រប់គ្រងកំណើនចំនួនប្រជាពលរដ្ឋ។

**ក-កំនើនប្រជាជន**

យើងដឹងហើយថាព្រៃឈើ និងធនធានមានតំលៃមិនអាចកាត់ថ្លៃបាន ចំពោះមនុស្សជាតិ និងសត្វនៅលើផែនដី។ ដោយមើលឃើញនៅសារៈសំខាន់របស់ធនធានធម្មជាតិ រាជរដ្ឋាភិបាលកម្ពុជា បានយកចិតទុកដាក់យ៉ាង ខ្លាំងទៅលើការអភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាពសំដៅបំរើឱ្យផលប្រយោជន៏សង្គម សេដ្ឋកិច្ច និងបរិស្ថាន សំរាប់មនុស្សជំនាន់បច្ចុប្បន្ននិងទៅអនាគតផងដែរ ក៏ប៉ុន្តែវានៅតែជាបញ្ហានៅពេលដែលកំនើនប្រជាជនកើនកើនឡើងយ៉ាងឆាប់រហ័ស ដែលតំរូវឱ្យមានការកាប់ទន្ទ្រាន ព្រៃយកដីធ្វើកម្មសិទ្ធិ ។

តាមទូលេខនៃការស្រាវស្រាវក្នុងឃុំ អាចបញ្ជាក់អំពីកំនើនប្រជាជនរហូតដល់ ......% ក្នុង ១ឆ្នាំ ក្នុងនោះបានប្រើប្រាស់ធនធានធម្មជាតិ រហូតដល់ .......% ក្នុង ១ ហិចតា ដែលកត្តាទាំអស់នេះ នាំមានការកាប់ទន្ទ្រានដីព្រៃ យ៉ាងអនាធិបតេយ្យក្នុងអំឡុងឆ្នាំ រហូតដល់ឆ្នាំ ២០០៨។

មូលហេតុនៃកំនើន

- តំបន់នេះជាតំបន់រក្សាទុក ប្រជានលួចកាប់ទន្ទ្រាន រានយកដី ពត័របងធ្វើកម្មសិទ្ធិដើម្បីយកដីលក់
- មានការផ្លាស់ប្តូរមុខរបរចិញ្ចឹមជីវិត ប្តូរពីកសិកម្មធ្វើចំការ មកប្រកបរបរនេសាទ។

**ខ-គ្រោះធម្មជាតិ ការវិចរិលនៃធម្មជាតិ**

បញ្ហាគ្រោះធម្មជាតិនៅតែស្ថិតនៅប្រឈមសំរាប់ធម្មជាតិ ដែលមិនអាចកាត់ផ្តាច់បាន តួយ៉ាងបញ្ហាបាត់បង់ផលនេសាទ នៅក្នុងតំបន់។ យោងតាមស្ថិតិកាលពីឆ្នាំ ២០០៦ ផលនេសាទអាចទទួលរហូតដល់ ៧៣.៤៤០ គីឡូក្រាម តែមកដល់ ឆ្នាំ២០០៨ បញ្ហាកង្វះផលនេសាទ ធ្លាក់ចុះ ៤.១៩៥ គីឡូក្រាម។ មួយវិញទៀតអំពីបញ្ហាចាក់លុបដីសមុទ្រ ព្រែក កំពុងតែរាតត្បាតយ៉ាងខ្លាំងពីសំណាក់ អ្នកមានលុយ មានឥទ្ធិពល មានអំណាច ដូចជាការបូមកកាយយកដីខ្សាច់នៅក្នុងសមុទ្រលក់ឱ្យប្រទេសក្រៅ បង្កឱ្យមានផលប៉ះពាល់ដល់ប្រពន្ធ័អេកូឡូស៊ីនៅបាតសមុទ្រ នៅតែមានជាបន្តបន្ទាប់ពីសំណាក់អ្នកមានអំណាច ធ្វើអោយបាត់លំនឹងប្រព័ន្ធអេកូឡូស៊ីក្នុងសមុទ្រ។

ក្នុងឃុំទំនប់រលក មានបញ្ហាប្រឈមជាច្រើន តែបញ្ហាប្រឈមដែលមានការពាក់ព័ន្ធដល់ធនធានធម្មជាតិក៏ដូច ជាការប្រើប្រាស់ដីមានដូចខាងក្រោម :

- ដីចំការបាត់បង់ដីជាតិ ដែលមានមូលហេតុជាអាទិ៍មកពី ការបាត់បង់ព្រៃឈើ ការធ្វើកសិកម្ម

- មិនមានបច្ចេកទេសគ្រប់គ្រាន់ការដាំដំណាំដដែលៗលើផ្ទៃដីតែមួយការប្រើប្រាស់ជីគីមីមិនត្រឹមត្រូវ ដែលធ្វើឱ្យដីខ្សោះជីជាតិ និងខូច រចនាសម្ព័ន្ធដី

- ទិន្នផលចុះទាប ដោយមកពីកត្តាដី មិនមានប្រព័ន្ធស្រោចស្រពការប្រើប្រាស់ពូជមិនបានត្រឹមត្រូវជម្ងឺនិងសត្វល្អិតបំផ្លាញ

- តម្រូវការដីបន្ថែម ដើម្បីបង្កបង្កើនផល

- ការកាប់រុករាន ទន្ទ្រាន ព្រៃលិចទឹក និងដីផ្សេងៗកាន់កាប់យកធ្វើជាដីកម្មសិទ្ធ

- ផ្ទៃដីព្រៃលិចទឹកមួយចំនួនទៀត ត្រូវបានដុតព្រៃ ដើម្បីផលប្រយោជន៍ ផ្សេងៗ ដូចជា ដុតព្រៃចាប់ សត្វអណ្តើក ,កន្ធាយ,ពស់ ដើម្បីបោះបង្គោលយកដីធ្វើកម្មសិទ្ធិផ្ទាល់ខ្លួនសំរាប់ទុកលក់, ។ល ។

ការប្រឈមទាំងអស់ខាងលើនេះ នឹងនាំមកនូវតម្រូវការដីកាន់តែច្រើន ដែលក្នុងនោះមានទាំងដីសំរាប់បង្កបង្កើនផល និងដីសំរាប់តែកម្មសិទ្ធិ ហើយជាលទ្ធផលរួមគឺ ការបាត់បង់ ព្រៃលិចទឹក វាលស្មៅ និងចំណីធ្នេរធម្ម ជាតិ ហើយនាំទៅដល់ការបាត់បង់ ធនធានព្រៃឈើ ធនធានជលផល ជីវៈចំរុះ ហើយបច្ច័យចុងក្រោយគឺធនធានដីកាន់តែរេចរិលជាបន្តបន្ទាប់ ។



## ២.២.២ ការប្រឈមដោយ ការអភិវឌ្ឍន៍ ដែលពុំមាននិរភាព

### គំរោងអភិវឌ្ឍន៍

- ខ្វះការថែទាំផ្លូវលំ ខូចផ្លូវនៅរដូវវស្សា ទាមទាការជួសជុលរៀងរាល់ឆ្នាំ
- កុមារចំនួន ១១៩ នាក់ ស្មើនឹង ២២.៧៧% មិនបានចូលរៀន
- ខ្វះប៉ុស្តិ៍សុខភាព( មណ្ឌលសុខភាពនៅឆ្ងាយ)

- ខ្វះទឹកស្អាតប្រើប្រាស់
- ខ្វះទឹកន្លែងចាក់សំរាម



**អំពើអនាធិបតេយ្យ**

- ការសង់ផ្ទះលើចំណីព្រែក ចំណីសមុទ្រ ចំណីផ្លូវ
- ការនេសាទត្រី ប្រើឧបករណ៍ខុសច្បាប់
- ការកាន់កាប់ដីតំរបព្រៃបៃតង
- ការចាក់លប់ដីសមុទ្រធ្វើជាលំនៅដ្ឋាន។



**ឱកាស**

**ដោយអំណោយផលធម្មជាតិ**

- មានមច្ឆាជាតិ
- ដីជាប់នឹងសមុទ្រ
- ទឹកមានជម្រៅល្មមបង្កភាពងាយស្រួលក្នុងការសាងសង់ផែ។

**២.២.៣ ដោយគំរោងវិនិយោគ**

ឃុំទំនប់រលកមានគំរោងវិនិយោគលើវិស័យសេដ្ឋកិច្ច( រោងចក្របង្កក់ផលនេសាទសមុទ្រ)

## ២.៣ កំណត់ត្រូវការនៃការអភិវឌ្ឍន៍និងគោលដៅយុទ្ធសាស្ត្រឃុំទំនប់រលក

| | |
|---|---|
| - សាងសង់ផ្លូវបេតុង | មានប្រវែង ២៥០០ម៉ែត្រ |
| - សាងសង់ផ្លូវកៅស៊ូ | មានប្រវែង ២០០០ម៉ែត្រ |
| - សាងសង់ផ្លូវក្រាលគ្រួសក្រហម | មានប្រវែង ៥០០០ម៉ែត្រ |
| - ដាក់លូទោល និងលូភ្លោះកាត់ផ្លូវ | ២៥ កន្លែង |
| - សាងសង់អាគារទីចាត់ការសាលា | ០១ ខ្នង |
| - សាងសង់បង្គន់អនាម័យ | ចំនួន ២០០ បង្គន់ |
| - រៀបចំកន្លែងផ្ទុកកាកសំណល់ | ០១ កន្លែង |
| - សាងសង់លូបង្ហូរទឹកភ្លៀង | ប្រវែង ៥០០០ម៉ែត្រ |
| - ដាក់ផ្លាកលេខតាមផ្ទះ | ចំនួន ១៦០០ផ្ទះ |
| - គំរោងចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធ | ០១ លើក |
| - សាងសង់ស្ពានបេតុង | ០១ កន្លែង |
| - ជួសជុលទំនប់បង្វៀរ | ០១ កន្លែង |
| - ស្តារបាតអាង | ០១ កន្លែង |
| - ជីប្រឡាយជុំវិញអាងទឹក | ប្រវែង ២០០០ ម៉ែត្រ |
| - ខួងអណ្តូងស្នប់ | ចំនួន ០២ អណ្តូង |
| - សាងសង់អាគារសិក្សា | ចំនួន ០៤ ខ្នង ( ១០បន្ទប់) |
| - រៀបចំសួនកំសាន្តក្នុងសាលា | ០១ កន្លែង |
| - ដាំដើមកោងកាង | ចំនួន ២០.០០០ ដើម( ភូមិ១) |
| - ឡដុតកាកសំណង់ | ០១ កន្លែង |
| - សាងសង់សាលាឃុំថ្មី | ០១ ខ្នង |
| - ស្លាកលេខផ្លូវ | ចំនួន ២០ ខ្សែ |

## ២.៤ តម្រូវការជីវភាពអនាគត

### ២.៤.១ ប្រជាសាស្ត្រ

**ក -អត្រាកំណើនមធ្យម( កំណើនធម្មជាតិ)**

ស្ថានភាពអត្រាកំណើននៃប្រជាពលរដ្ឋនៅក្នុងឃុំទំនប់រលក បើពិនិត្យទៅតាមបណ្ដាឆ្នាំនិមួយៗឃើញថាមិនមានការកើនឡើងទេព្រោះប្រសិនបើមើលទៅលើចំនួនគ្រួសារក៏មានការថយចុះដែរព្រោះប្រជាជនធ្វើចំណាកស្រុក ។

ចាប់ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៥ ប្រជាពលរដ្ឋមានកំណើនថយចុះ -៤% ដល់ -៥% ។ ប៉ុន្តែអត្រានេះមានកើនថយសំរាប់ឆ្នាំ ២០០៧ ក្នុងអត្រា -៣% ឆ្នាំ ២០០៨ អត្រា -២% ។

ប្រជាពលរដ្ឋនឹងមានកំណើនលឿនហួសពីការគ្រោងទុក នៅពេលដែលតំបន់សេដ្ឋកិច្ចពិសេសដំណើការ ។

**២.៤.១.១ អត្រាកំណើនមធ្យម ( កំណើនធម្មជាតិ )**

| ចំនួនគ្រួសារ/ប្រជាជន | ចំនួនគ្រួសារ/ប្រជាជនតាមឆ្នាំ | | | | | កំណើនប្រជាសាស្ត្រ | |
|---|---|---|---|---|---|---|---|
| | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | កំណើនមធ្យម | កំណើនឆ្នាំ |
| ចំនួនគ្រួសារសរុប | ១៤៨៥ | ១៤១៥ | ១៣៥២ | ១៣៧៥ | ១៣៣៧ | - | - |
| អត្រាកំណើនគ្រួសារ | | -៥% | -៤% | ២% | -៣% | ៣% | ៦១ |
| ចំនួនប្រជាជនសរុប | ៨០៥៨ | ៧៧៤៦ | ៧២៥៦ | ៧៣០៣ | ៧១៨៤ | - | - |
| អត្រាកំណើនប្រជាជន | | -៤% | -៦% | ១% | -២% | ១% | ១០១ |

នៅក្នុងអត្រា នៃការប្រែប្រួលចំនួនគ្រួសាររបស់ប្រជាពលរដ្ឋ នៅក្នុងអំឡុងឆ្នាំ ២០០២ ដល់ ឆ្នាំ ២០០៣ ឃើញថា មានការកើនឡើង ៣ភាគរយ ប៉ុន្តែពីឆ្នាំ ២០០៣ ដល់ ឆ្នាំ ២០០៤ អត្រាកំណើនមានការប្រែប្រួលគឺទាំងនេះ តាមពត៌មាន បានអោយដឹងថា អាស្រ័យប្រជាជាជន មានការយល់ដឹង ពី កម្មវិធីពន្យាកំណើត ពិសេសគឺការធ្វើចំណាកស្រុកទៅធ្វើចំការនៅព្រំដែន ហើយនិងមួយចំនួនទៀតត្រូវទៅធ្វើជាកម្មករសំណង់ និងកម្មករ តាមក្រុមហ៊ុននានានៅភ្នំពេញ។ ក្នុងនេះដែរបើតាមការគណនាអត្រាកំណើនចំនួនគ្រួសារ ពីឆ្នាំ ២០០២ ដល់ ឆ្នាំ២០០៨ ឃើញថា អត្រាកំណើនមាន ៣% ក្នុងមួយឆ្នាំ ។

ផ្អែកតាមទិន្នន័យពត៌មាននៃផែនការអភិវឌ្ឍន៍ឃុំនិងតាមរយៈការគណនារកអត្រាកំណើនរបស់ប្រជាពល រដ្ឋឃើញថាចំនួនប្រជាជន ពីមួយឆ្នាំ ទៅមួយឆ្នាំ មានការប្រែប្រួល កើនឡើង និងឆ្នាំខ្លះមានការ ថយចុះកត្តានេះគឺអាស្រ័យដោយមូលហេតុដូចករណីខាងលើ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏អត្រាកំណើនជាមធ្យម

**២.៤.១.២ ការធ្វើចំណោលប្រជាសាស្ត្រ**

តារាងការធ្វើចំណោលប្រជាសាស្ត្រ

| ស្ថិតិតាមក្រុមអាយុ | ឆ្នាំ ២០១២ | | ឆ្នាំ ២០១៧ | | ឆ្នាំ ២០២២ | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អាយុក្រោម០៥ឆ្នាំ | ៩៧២ | ៤៧៣ | ១០១៩ | ១០៩០ | ១០៦៥ | ៥១៨ |
| អាយុ ០៥ឆ្នាំ | ៣២២ | ១៥២ | ៣៣៨ | ១៥៩ | ៣៥៣ | ១៦៦ |
| អាយុពី ៦-១១ឆ្នាំ | ១២២៨ | ៦១០ | ១២៨៧ | ៦៤០ | ១៣៤៦ | ៦៦៩ |
| អាយុពី ១២-១៤ឆ្នាំ | ៧៣៩ | ៣៥៨ | ៧៧៥ | ៣៧៥ | ៨១០ | ៣៩២ |
| អាយុពី ១៥-១៧ឆ្នាំ | ៨១២ | ៣៩៧ | ៨៥១ | ៤១៦ | ៨៩០ | ៤៣៥ |
| អាយុពី ១៨-២៤ឆ្នាំ | ១៥៥៧ | ៧៥៥ | ១៦៣១ | ៧៩១ | ១៧០៦ | ៨២៧ |
| អាយុពី ២៥-៦០ឆ្នាំ | ៤៤២៥ | ២១៥៩ | ៤៦៣៧ | ២២៦២ | ៤៨៤៩ | ២៣៦៥ |
| អាយុពី៦១ឆ្នាំឡើងទៅ | ៤៩៧ | ២៥៤ | ៥២១ | ២៦៦ | ៥៤៥ | ២៧៨ |
| **ចំនួនប្រជាជនសរុប** | **១០៥៥៣** | **៥១៥៧** | **១១០៥៨** | **៥៤០៤** | **១១៥៦៣** | **៥៦៥១** |
| **ចំនួនគ្រួសារសរុប** | **២០៩៧** | | **២១៩៨** | | **២២៩៨** | |

<u>**កំណត់សំគាល់ :**</u> ប្រជាពលរដ្ឋនឹងមានកំណើននៅពេលតំបន់សេដ្ឋកិច្ចពិសេសដំណើការ ចំនួន ប្រជាជន នៅឆ្នាំ ២០២២ មានចំនួនសរុប ១១៥៦៣ នាក់ ។

- ដង់ស៊ីតេ ៣១នាក់/គម$^{២}$ ( តាមផ្ទៃដីរបស់ឃុំ ៥.២៣២ ហិកតា)
- ដង់ស៊ីតេ ៣២ នាក់/ គម$^{២}$ ( តាមផ្ទៃដីរបស់ GIS )

អត្រាកំណើនប្រជាពលរដ្ឋនៅក្នុងឃុំទទប់រលកបើពិនិត្យទៅលើកំណើនក្នុងរយៈពេល៥ឆ្នាំម្តង សំរាប់រយៈពេល ១៥ឆ្នាំខាងមុខ ឃើញថាអត្រាកំណើនប្រជាពលរដជាមធ្យម១ % ក្នុងនោះ ស្មើនិង ១០១ នាក់ ក្នុងមួយឆ្នាំហើយនិង៣%ស្មើនិង៦១ គ្រួសារ ក្នុងមួយឆ្នាំ នោះ បើពិនិត្យទៅលើ បរិមាណផ្ទៃដី ដែលអាចប្រើប្រាស់បាននៅមានកំរិត ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏យើងត្រូវចាប់អារម្មណ៏ដល់ការអភិវឌ្ឍ ដែរ ព្រោះអត្រា កំណើនរបស់ប្រជាពលរដ្ឋនៅក្នុងឃុំទំនប់រលក គឺវាពាក់ពន្ធ័ទៅលើការអភិវឌ្ឍធនធាន ដែលមានក្នុងឃុំ ពិសេសបរិមាណដីដែលអាចបង្កើននូវបរិមាណផល ដើម្បីធានាស្បៀងក្នុងតំបន់ ។

ឃុំទំនប់រលកមានប្រជាជនសរុប ចំនួន ២០១៧ គួសារ ត្រូវជា ៧១៨៤ នាក់ ក្នុងនោះស្រី ៣៦៣៦នាក់ ស្ត្រីមេមាយជាមេគ្រួសារ ២៥៩ គ្រួសារ និងជនពិការជាមេគ្រួសារមានចំនួន ៣៣ គ្រួសារ ។

### ២.៤.២ <u>តម្រូវការដីសំរាប់លំនៅដ្ឋាន</u>

ដីលំនៅដ្ឋានឃុំទំនប់រលកបច្ចុប្បន្នមានផ្ទៃដី ១៩៤ ហិកតា ( ទិន្នន័យឃុំ) ដូច្នេះក្នុងមួយគ្រួសារជាមធ្យម មានសមាជិកចំនួន ០៥ នាក់ដែលទទួលបានផ្ទៃដី ១០ ម x ២៦ ម គិតជាមធ្យមមនុស្សម្នាក់ ទទួលបាន ២៦៦.៤២ ម$^{២}$ ដល់ឆ្នាំ ២០២២ ប្រជាជនក្នុងឃុំកើនដល់ ១១៥៦៣ នាក់ ជាមធ្យមក្នុង ១ គ្រួសារ ១០ ម x ២៦ ម មនុស្សម្នាក់ ទទួលបាន ២៣៣.៥២ ម$^{២}$ ។

### ២.៤.៣ តម្រូវការដីកសិកម្ម

តម្រូវការដីកសិកម្ម គឺរួមមានដីសំរាប់ចំការដំណាំ សំរាប់ឆ្នាំគោល ២០០៨ មានទំហំ ២០៤ ហិកតា (ទិន្នន័យឃុំ) សំរាប់ប្រជាជនសរុប ៧៤២ គ្រួសារ ចំពោះឃុំ ទំនប់រលក មិនមានតំរូវការដីកសិកម្មច្រើនទេ ដោយ ឃុំនេះពុំមានធ្វើស្រែ ហើយពុំមានដីពង្រីកសំរាប់កសិកម្ម ។(យោងតាមការសួរក្រុមប្រឹក្សាឃុំ)

ដូច្នេះទំហំដីជាមធ្យមសំរាប់ ០១ គ្រួសារមាន ០,២៧ហិកតា សំរាប់ដំណាំឧស្សាហកម្មនិងដាំណាំផ្សេងៗ

- តំរូវការដីសំរាប់ឆ្នាំ ២០២២ មាន :
  - ចំនួនគ្រួសារបច្ចុប្បន្នត្រូវមានដីកសិកម្ម ៧៤២ គ្រួសារ x ០,២៧ = ២០៤ហ.ត
  - កំណើនគ្រួសារឆ្នាំ២០២២ ២២៩៨ គ្រួសារ x ០,២៧ = ៦២០.៤៦ ហ.ត

**សរុប ៨២៤,៤៩ហ.ត**

### ២.៤.៤ តម្រូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ

ដោយនៅឃុំទំនប់រលកនៅមានព្រៃលិចទឹក និងវាលស្មៅ ដូច្នេះដីដែលបានកំណត់នៅក្នុង តំបន់រសើប និងដីផ្សេងៗទៀតដែលមិនបានកំណត់ទៅក្នុងប្រភេទប្រើប្រាស់ដីផ្សេងៗទៀត គឺត្រូវតែទុកឱ្យនៅជាដីព្រៃ និងវាលស្មៅសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ពិសេសគឺបណ្តោយឆ្នេរសមុទ្រ ព្រៃកធម្មជាតិដែលជាប្រភពដ៏ចំបងសំរាប់ធនធានជលផល ។

#### ២.៤.៤.១ ដីព្រៃឈើ

ព្រៃឈើ គឺជាជីវិត និងវប្បធម៌របស់ពលរដ្ឋកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់លើវិស័យព្រៃឈើ និងដាក់ចេញនូវគោលការណ៍សហសវត្ស ដែលផ្តោតលើការការពារ ថែរក្សាគំរបព្រៃឈើ ១០៥០ ហិចតា (យោងតាមទិន្នន័យរបស់ឃុំ) នូវឆ្នាំ ២០១៥ និងលើសពីនេះបានដាក់ចេញនូវ គោលនយោបាយចតុកោណ ដែលផ្តោតលើការគ្រប់គ្រង ធនធានព្រៃឈើ និងអភិរក្សជីវចំរុះ ការពារបរិស្ថានធម្មជាតិ រួមចំណែកកាត់បន្ថយ ភាពក្រី ក្រ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។ ធនធានព្រៃឈើដែលកើតឡើងវិញ អាចនាំមកនូវប្រាក់ចំណូលជាបន្តបន្ទាប់ បើសិនព្រៃឈើទាំងនោះ ត្រូវបានគ្រប់គ្រងអោយមាននិរន្តភាព។ ប្រព័ន្ធអេកូឡូស៊ីព្រៃឈើ ដើរតួនាទីយ៉ាងសំខាន់ ដូចជា : ស្រូបយកសារធាតុពុលពីក្នុងខ្យល់ ធ្វើអោយមានដំណើរការជុំ នៃសារធាតុចិញ្ចឹម បង្កើតជាជីវជាតិដី ទប់ទល់ការហូរច្រោះ និងការកែសម្រួលធាតុអាកាស ការពារទេសភាពធម្មជាតិ ព្រមទាំងផ្តល់ផលិតផល និងសេវាសំខាន់ៗ ជាអាទិ៍ដូចជា : ផ្តល់ជាឥន្ទនៈ សំភារៈសាងសង់ និងឱសថបុរាណ។ ដូច្នេះ ឃុំបានរៀបចំបង្កើតសហគមន៍ព្រៃឈើ សំរាប់គោលបំណងការពារបរិស្ថានក្នុងឃុំ និងសំរាប់ផ្តល់ផលការផ្គត់ផ្គង់ឈើសំរាប់ថាមពល។

**ត្រៀមបំរុងសំរាប់គោលបំណងផ្សេងៗ**

សំរាប់សហគមន៍ព្រៃឈើ តំបន់ទេសចរណ៍ធម្មជាតិ ។

### ២.៤.៤.២ ធនធានទឹក

ឃុំទំនប់រលក មានអាងស្តុកទឹកសាបចំនួន ០១ កន្លែង សំរាប់ស្រោចស្រពទៅលើដំណាំ សត្វផឹក និង មនុស្សមានការចិញ្ចឹមត្រី មានទំហំផ្ទៃដី ៤.០១៩៦ ហិចតា។

- មានការចិញ្ចឹមត្រីទឹកប្រៃ ០១ កន្លែង



## ២.៤.៥ តម្រូវការដីសំរាប់ ហេដ្ឋារចនាសម្ព័ន្ធសង្គម

### ២.៤.៥.១ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និង ប្រព័ន្ធសង្គម

ហេដ្ឋារចនាសម្ព័ន្ធសង្គមក្នុងរូបភាពតូចតាច គឺត្រូវបានបញ្ចូលទៅក្នុងដីលំនៅដ្ឋាន ដោយមិនបានញែកចេញដោយឡែកនោះទេ(ក្នុងនោះមានដីកប់ខ្មោច ទីលានចាក់សំរាម គិតគូក្នុងនោះដែរ)តែក៏មានការគិតគូរជារួមលើកលែងតែដីហេដ្ឋារចនាសម្ព័ន្ធសង្គមដែលមានទ្រង់ទ្រាយធំ ទើបមានការគិតគូរដោយឡែក។

- ផ្លូវថ្មីមាន ១៧ ខ្សែ

ដីសំរាប់កសាងហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម(រោងចក្របង្កក់ផលនេសាទ ០១ កន្លែង)

តារាងផែនការអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មទូទៅ

| ហេដ្ឋារចនាសម្ព័ន្ធ | ចំនួនក្នុងឆ្នាំនេះ | ចំនួន១៥ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាមត្តេយ្យ | ០១ | ០០ | ០០ |
| សាលាបឋមសិក្សា | ០១ | ០៣ | ០២ |
| សាលាអនុវិទ្យាល័យ | ០១ | ០៣ | ០២ |
| សាលាវិទ្យាល័យ | ០០ | ០៤ | ០៤ |

| | | | |
|---|---|---|---|
| មណ្ឌលសុខភាព | 0 | 0 | 0 |
| ប៉ុស្តិសុខភាព | 0 | ១ | ១ |
| ស្នាក់ការសហគមន៍នេសាទ | ១ | ៣ | ២ |
| ស្រះទឹកស្អាត | ៥ | 0 | 0 |
| អណ្តូងទឹកស្អាត | ២១0 | 0 | 0 |
| អណ្តូងស្នប់ | ៦៩ | 0 | 0 |
| អណ្តូងលូជីកដោយដៃ | ៩៣ | 0 | 0 |
| អណ្តូងដៃដាក់លូ មិនរៀបឥដ្ឋ | ៤៨ | 0 | 0 |
| កន្លែងចាក់សំរាម | 0 | ១ | ១ |
| ទីតាំងផ្សារ | ១ | 0 | 0 |
| អាងស្តុកទឹក | ១ | 0 | 0 |
| ប៉ុស្តិនគរបាល | ១ | 0 | 0 |

តារាងការអភិវឌ្ឍន៍ហេដ្ឋាផ្នែករចនាសម្ព័ន្ធរូបវ័ន្ត

| ប្រភេទហេដ្ឋារចនាសម្ព័ន្ធ | ប្រវែងផ្លូវឆ្នាំនេះ (ម) | ប្រវែងផ្លូវ១៥ឆ្នាំ (គ.ម) | បំរែបំរួល |
|---|---|---|---|
| ផ្លូវក្រាលកៅស៊ូ | ២000 | ៤000 | ២000 |
| ផ្លូវក្រាលគ្រួសក្រហម | ៥000 | ១0.000 | ៥.000 |
| ប្រវែងផ្លូវបេតុង | ២៥00 | ៥000 | ២៥00 |
| ចំនួន ស្ពានថ្ម | ១ | ២ | ១ |
| ចំនួនលូឆ្លងផ្លូវ | ៩ | ៩ | ១៨ |

### ២.៤.៥.២ តម្រូវការដីសាលារៀន

ផ្ទៃដីសំរាប់សាងសង់សាលារៀនថ្មីនៅក្នុងឃុំនេះមិនមានទេ ហើយប្រសិនបើតម្រូវអោយមានការសាងសង់បន្ទប់រៀនថ្មី គឺអាចធ្វើការសាងសង់នៅក្នុងបរិវេណសាលាចាស់បាន ។

ផ្ទៃដីសំរាប់សាងសង់សាលារៀននៅក្នុងឃុំនេះ គឺមិនមានការកំណត់ផ្ទៃដីឱ្យបានច្បាស់លាស់នោះទេដោយកន្លងមកដីសាលាត្រូវបានគិតបញ្ចូលទៅក្នុងដីលំនៅដ្ឋានហើយប្រសិនបើតម្រូវឱ្យមានការសាងសង់បន្ទប់រៀនថ្មីគឺអាចធ្វើការសាងសង់នៅក្នុងបរិវេណសាលាចាស់បាន លើកលែងតែ មានការសាងសង់ជាសាលាថ្មី ។

ចំពោះការអភិវឌ្ឍន៍ និងប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ សង្គម នៅក្នុងមូលដ្ឋានឃុំ បច្ចុប្បន្ន នៅមានកំរិតដោយជាបណ្តើរៗកំពង់ដំណើរការអភិវឌ្ឍន៍ ដូចជា នៅចុងឆ្នាំ២00៦ និងដើមឆ្នាំ ២00៧ បានសាងសង់នូវអនុវិទ្យាល័យមួយកន្លែង និងមួយអាគារកើតថ្មី ប៉ុន្តែទោះបីយ៉ាងនេះក៏ដោយ ក៏ការអភិវឌ្ឍន៍លើវិស័យអប់រំនៅក្នុងឃុំនៅពុំទាន់បំពេញបាននូវតម្រូវការសិក្សារបស់ សិស្សានុសិស្ស នៅឡើយ ជាអាទិ៍ដូចជា នៅគម្រោង ផែនការ១៥

ឆ្នាំខាងមុខតម្រូវការលើ អាគារសិក្សា ផ្អែកតាមបរិមាណ សិស្សានុសិស្ស គឺ សាលាមតេយ្យ សាលាបឋមសិក្សា ក៏ដូចជា អនុវិទ្យាល័យ វិទ្យាល័យ បើពិនិត្យទៅតាមការគណនា កំណើនប្រជាពលរដ្ឋ ឃើញថា តម្រូវការទាំងនេះ អាចផ្តល់ឱកាសអោយឃុំ ទំនប់រលក អាចអភិវឌ្ឍន៏ ទៅតាមលទ្ធភាព ជាបណ្តើរៗ។

តារាងកំណើនកុមារ និងតម្រូវការថ្នាក់រៀននិងសាលានៅឆ្នាំ២០១២-២០២២

| ប្រភេទសាលា | នៅឆ្នាំ ២០១២ | | | នៅឆ្នាំ ២០១៧ | | | នៅឆ្នាំ ២០២២ | | |
|---|---|---|---|---|---|---|---|---|---|
| | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ |
| ថ្នាក់មត្តេយ្យសិក្សា | ៣២២ | ០ | ១ | ៣៣៨ | ០ | ២ | ៣៥៣ | ០ | ១ |
| ថ្នាក់បឋមសិក្សា | ១២២៨ | -៤ | -១៨ | ១២៨៧ | -១ | -៥ | ១៣៤៦ | ២ | ៩ |
| ថ្នាក់អនុវិទ្យាល័យ | ៧៣៩ | ០ | ២ | ៧៧៥ | ២ | ១០ | ៨១០ | ០ | -២ |
| ថ្នាក់វិទ្យាល័យ | ៨១២ | ២ | ៨ | ៨៥១ | ០ | ០ | ៨៩០ | ២ | ៩ |

### ២.៤.៥.៣ <u>សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត</u>

**ក. <u>សេវាកម្មសុខភាព</u>**

ឃុំទំនប់រលកពុំមានមណ្ឌលសុខភាពទេ។ដូច្នេះនាពេលអនាគតឃុំនឹងបង្កើតប៉ុស្តិ៍សុខភាពនៅក្នុងឃុំទំនប់រលក ដើម្បីពិនិត្យ និងព្យាបាលជូនប្រជាពលរដ្ឋ។

បច្ចុប្បន្នសេវាសុខភាពនៅក្នុងឃុំ ពុំទាន់មាននូវសេចក្តីត្រូវការរបស់ប្រជាជនទូទាំងឃុំបានឡើយ ព្រោះ មានភូមិទាំង ៤ ស្ថិតនៅឆ្ងាយពីមណ្ឌលសុខភាព។

ចំពោះការការពារសុខមាលភាពប្រជាពលរដ្ឋនៅក្នុងឃុំទំនប់រលក នៅចោទជាបញ្ហា ហើយនៅរយៈពេល ១៥ ឆ្នាំ ខាងមុខ ក៏នៅតែជួបបញ្ហាដដែល ព្រោះថា ស្ថានភាពប្រជាជន ក្នុងឃុំ រស់នៅតំបន់តាមឆ្នេរសមុទ្រ មាន ចំនួន ៤ ភូមិ និងនៅលើផ្ទៃទឹក លើឆ្នេរសមុទ្រ ធ្វើអោយប៉ះពាល់ដល់បរិស្ថានតំបន់ឆ្នេរ ធ្វើអោយខូចគុណភាពទឹក កខ្វក់តាមមាត់ឆ្នេរស្អុយ សំណល់ដែលចោលលើផ្ទៃទឹកខូចសុខភាព ប្រជាពលរដ្ឋទូទាំងឃុំឡើយ។ ដូច្នេះកង្វះខាត លើ មណ្ឌលសុខភាព គឺជាកត្តាសំខាន់ ប៉ុន្តែបើពិនិត្យទៅលើ ស្តង់ដា នៃការបង្កើតមណ្ឌលសុខភាព មានកំរិតខ្ពស់ ហើយនៅរយៈពេលខាងមុខយើងមិនអាចបង្កើតបាន ជាគោលការបើពិនិត្យទៅលើ ប៉ុស្តិសុខភាពថ្មីឡើងវិញ ។ ឃើញថាពុំទាន់មានតំណើការ ដូច្នេះជាអាទិភាព ឃុំត្រូវលើកផែនការសាងសង់ ប៉ុស្តិ៍សុខភាព អោយមាន នៅតាម ភូមិនីមួយៗ ទើបអាចជួយសំរាលដល់ ការលំបាក លើថែទាំសុខភាពក្នុងមូលដ្ឋាន ក្នុងនោះ បង្កើត នៅភូមិ ២ ទល់មុខសាលាឃុំទំនប់រលក ងាយស្រួលដល់ឃុំទាំង ៣ ទៀត។

**ខ.<u>ការផ្គត់ផ្គង់ទឹកស្អាត</u>**

ការប្រើប្រាស់ទឹកស្អាតនៅក្នុងឃុំទំនប់រលកបច្ចុប្បន្ន នៅតែជាបញ្ហាចំបងនៅឡើយ ព្រោះថាចំពោះអណ្តូង ទឹក និងស្រះទឹក នៅក្នុងឃុំ ដែលបានសាងសង់ពីមុននោះ មួយចំនួនត្រូវបានខូច ដូច្នេះ ជាជំហ៊ានដំបូងនៃការ អភិវឌ្ឍន៍ ត្រូវស្តារ និងជួសជុល នូវប្រភពទឹកស្អាតទាំងនេះ ហើយជាផែនការនៅពេលខាងមុខ ឃុំត្រូវបន្ថែមនូវ

គម្រោងផែនការក្នុងការជីកស្រះស្តុកទឹកស្អាត ឃុំគួរតែស្នើទំនប់សហគមន៍ ធ្វើកន្លែងទឹកស្អាតប្រើប្រាស់ទូទាំងឃុំ បានធ្វើការជីកបន្ថែម បំផុសឱ្យប្រជាពលរដ្ឋជួយថែរក្សា នឹងបន្ថែមអណ្តូងទឹកស្អាត ។

នាពេលអនាគត ឃុំនឹងរៀបចំបណ្តាញទឹកស្អាតដែលមានប្រភពមកពីខេត្តព្រះសីហនុ។

**ផ្នែកវប្បធម៌និងសាសនា**

នៅក្នុងឃុំទំនប់រលកពុំមានវត្តទេ ។

**ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រព័ន្ធស្រោចស្រព**

ផ្អែកតាមស្ថានភាពជាក់ស្តែងនៃបរិមាណផ្លូវដែលមានក្នុងឃុំទំនប់រលកឃើញថា ផ្លូវមាន១៨ខ្សែ ត្រូវធ្វើការកែលំអឡើងវិញ ចំនួនត្រូវធ្វើការកែលំអរដូចជា ផ្លូវគ្រួសក្រហម ដែលបានសាងសង់ពីមុនមកបច្ចុប្បន្នត្រូវបាន ខូចដោយសារទឹកភ្លៀង គ្មានប្រពន្ធ័លូគ្រប់គ្រាន់ ឡានដឹកហួសចំណុះ ហើយនៅក្នុងឆ្នាំ ២០០៨ នេះឃុំបាន ធ្វើការជួសជុលឡើងវិញបាន ១ ខ្សែ ប្រវែងសរុប ៤.៨១៩ ម៉ែត្រ. ហើយនៅសល់ពីនោះចំនួន ១៧ ខ្សែ ឃុំ និងធ្វើការជួជុលបន្ត ហើយនៅរយៈពេល ១៥ ឆ្នាំ ខាងមុខឃុំ និងលើកគម្រោងសាងសង់ផ្លូវគ្រួសក្រហមបន្ថែម លើផ្លូវដីសប្រវែង ៥០០០ ម ជាមួយគ្នានេះដែរឃុំក៏បានលើកគម្រោងផ្លូវចាក់បេតុងមានប្រវែង ៩៣០ ម៉ែត្រ ឆ្នាំថ្មីធ្វើបន្តទៀត ។ផ្លូវកៅស៊ូលើផ្លូវគ្រួសក្រហម ស្ថិតនៅសង្កាង ដែលមានប្រវែង ២០០០ ម៉ែត្រ ឆ្នាំថ្មីឃុំធ្វើបន្ត។

ដោយឡែកចំពោះផ្លូវដីដែលត្រូវបាននោះគឺឃុំបានធ្វើការសិក្សាទៅលើផ្លូវចំនួន១៧ខ្សែ ដែលផ្លូវនិមួយៗមានទិសដៅចូលទៅតាមភូមិដែលត្រូវបានកើតថ្មី។ សូមបញ្ជាក់ថាមានផ្លូវមួយចំនួនដែលមានទ្រង់ទ្រាយជាផ្លូវចូលទៅលំនៅដ្ឋានដែរ ប៉ុន្តែមានទំហំធំជាងភ្លឺស្រែដូច្នេះមានផែនការដាក់បញ្ចូលផ្លូវនេះជាផ្លូវលំដីនិងធ្វើការសាងសង់អោយត្រូវតាមស្តង់ដា ) ។

នៅក្នុងដំណើរការអភិវឌ្ឍទៅលើប្រពន្ធ័ទឹក ឃុំបានធ្វើការសិក្សាទៅលើប្រភពទឹកដែលមានស្រាប់ដូចជាទំនប់ និង អណ្តូង ដោយផ្អែកទៅស្ថានភាពភូមិសាស្ត្រនិងលទ្ធភាព អំណោយផលរបស់ឃុំ នោះឃុំបានលើកគម្រោងផែនការអភិវឌ្ឍ សំរាប់រយៈពេល១៥ ឆ្នាំខាងមុខ ដោយធ្វើការសាងសង់ទំនប់ចំនួន១ ខ្សែប្រវែង ៤.០១៩៦ ហិចតាបន្ថែមទៀតនិងធ្វើបន្ថែមស្រះចំនួន៥ ។

ស្ថានភាពលំនៅដ្ឋានរបស់ប្រជាពលរដ្ឋឃុំភាគច្រើនរស់នៅតាមសងខាងផ្លូវគ្រួសក្រហម ដូច្នេះជាចាំបាច់ប្រជាជនត្រូវមានការឆ្លងទៅមកបញ្ហានេះជាបញ្ហាចោទសំរាប់ប្រជាជនឃុំ ព្រោះថ្ងៃអនាគតត្រូវកសាងស្ពានបេតុង ១ខ្សែព្រែកកោងកាងដែលអាចបំពេញបាននូវតម្រូវការឆ្លងបានគ្រប់គ្រាន់។ ផ្អែកតាមបញ្ហាខាងលើ ឃុំបានលើកគម្រោងផែនការលើការសាងសង់ស្ពានឈើចាស់ជាស្ពានថ្ម និង សាងសង់ស្ពានឈើថ្មី ។

ជាមួយគ្នានេះដែរគឺឃុំបានផ្តោតជាសំខាន់ទៅតាមតម្រូវការនៃការសាងសង់ប្រពន្ធ័ប្រឡាយទឹក ដែលឃុំបានលើកគម្រោងក្នុងនេះឃុំបានសិក្សានិងកំណត់បាន នូវចំនួនដែលត្រូវសង់ក្នុងពេលអនាគត។

បច្ចុប្បន្នលូឆ្លងផ្លូវនៅក្នុងឃុំទំនប់រលកមានការខូចខាត មួយចំនួន ដោយសារ ផ្លូវគ្រួសក្រហមត្រូវខូចខាត ធ្វើអោយលូត្រូវខូចបែក និងលុបដីជិតមិនអាចប្រើបាន ដូច្នេះតម្រូវការក្នុងពេលអនាគតតម្រូវអោយមានការ សាង

សង់លូឆ្លងផ្លូវ និង លូដោះទឹក ដែលក្នុងនៅមានទីតាំងនៅភូមិ ។

## ២.៤ បញ្ហាពាក់ពាន្ធ័ក្នុងការប្រើប្រាស់ដី ( បញ្ហា/ តម្រូវការ/ និងដំណោះស្រាយ ឃុំទំនប់រលក)

| បញ្ហា | ទីតាំង | មូលហេតុ | ដំណោះស្រាយ |
|---|---|---|---|
| ១-ព្រៃឈើបាត់បង់ | ភូមិ ១ | -ទន្ទ្រានយកដី | -ដាំកូនឈើឡើងវិញ<br>-បង្កើតសហគមន៏ព្រៃឈើ |
| ២-ធនធានជលផលថយចុះ | ភូមិ១-២-៣-៤ | -ឧបករណ៏នេសាទ<br>ខុសច្បាប់តម្រូវការកើន | -ផ្សព្វផ្សាយច្បាប់ជលផលបង្កើន<br>ការគាំទ្រសហគមន៏នេសាទ |
| ៣-បាត់បង់ព្រៃលិចទឹក | ភូមិ ១ | -ទន្ទ្រានយកដី | -ពង្រឹងការអនុវត្តន៏ច្បាប់<br>-ដាំព្រៃកោងកាងឡើងវិញ<br>-បង្កើនការគាំទ្រសហគមន៏<br>ការពារព្រៃលិចទឹក |
| ៤-បាត់បង់តំបន់ឆ្នេរ | ភូមិ១-២-៣-៤ | -ទន្ទ្រានយកដីឆ្នេរ<br>ពីសំណាក់អ្នកមានលុយ<br>មានអំណាចមួយចំនួនតូច | -រៀបចំតំបន់ឆ្នេរទេសចរណ៏<br>-បង្កើតសហគមន៏តំបន់ឆ្នេរ<br>ទេសចរណ៏ធម្មជាតិ<br>-រិតបន្តឹងច្បាប់បរិស្ថាន<br>-ផ្សព្វផ្សាយច្បាប់<br>អនុវត្តន៏ច្បាប់បន្ថែម<br>-ត្រូវអនុវត្តច្បាប់ផ្តន់ទាទោស |
| ៥-ខ្វះផ្លូវល្អធ្វើដំណើរ | ទូទាំងឃុំ | -ខ្វះលូបង្ហូរកាត់ផ្លូវ<br>ខ្វះប្រឡាយ<br>-ភ្លៀងហូរច្រោះ<br>-ខ្វះស្ពាន | -ស្តារ-ជួសជុលផ្លូវទាំងអស់<br>-សាងសង់ផ្លូវថ្មី២ខ្សែបន្ថែម( ៥.១)<br>-ធ្វើផ្លូវកៅស៊ូបន្ត<br>-ធ្វើផ្លូវបេតុងបន្ត<br>-សាងសង់លូអក្សរអ៊ុយកាត់ផ្លូវ<br>-ស្ពាន១ ( ៥.២ ) |
| ៦-ទំនាស់ដីធ្លី | ទូទាំងឃុំ | -គ្មានបណ្ណ័សំគាល់<br>កម្មសិទ្ធិ | -ផ្តល់បណ្ណ៏កម្មសិទ្ធិប្រើប្រាស់<br>ជាលក្ខណ:ប្រពន្ធ័<br>-ផ្សព្វផ្សាយច្បាប់ភូមិបាល |
| ៧-បញ្ហាកាកសំណល់ | ទាំង៤ភូមិ | ខ្វះការគ្រប់គ្រង | -ផ្សព្វផ្សាយការយល់ដឹងពី |

| | | | |
|---|---|---|---|
| | | កាកសំណល់<br>-ខ្វះការយល់ដឹង<br>-គ្មានកន្លែងចាក់<br>កាកសំណល់ | ផលប៉ះពាល់បរិស្ថាន<br>-រកទីតាំងចាក់កាកសំណល<br>-រកអ្នកម៉ៅការទទួលសេវា<br>ប្រមូលកាកសំណល់ |
| ៨-ខ្វះអាគារសិក្សា | ភូមិ៤ | -សិស្សកើនឡើង | -សាងសង់អាគារសិក្សា១ខ្នង<br>២ជាន់១២បន្ទប់<br>-សាងសង់បង្គន់អនាមយ័<br>សាលា៦បង្គន់<br>-សាងសង់ទីចាត់ការសាលា១ខ្នង<br>-សាងសង់អគារសិក្សាមតេយ្យ<br>១ខ្នងមាន៥បន្ទប់ |
| ៩-ការបង្ហូរកាកសំណល់<br>រឹងរាវចូលសមុទ្រ | ភូមិ១-២-៣-៤ | -ផ្ទះសង់តាមឆ្នេរ<br>លើទឹកសមុទ្រ<br>-បង្គន់ | -ផ្សព្វផ្សាយពង្រឹងការ<br>អនុវត្តន៏ច្បាប់បរិស្ថាន<br>-ផ្សព្វផ្សាយអប់រំពី<br>អនាមយ័បរិស្ថាន |
| ១០-ការចោលកាក<br>សំណល់ចូលក្នុងទឹកសមុទ្រ | ទាំង៤ភូមិ | -ខ្វះប្រពន្ធ័ប្រមូល<br>កាកសំណល់ | -រៀបចំប្រពន្ធ័ប្រមូល<br>កាកសំណល់។ |
| ១១-សាលាឃុំទ្រុឌទ្រោម | ភមិ១ ភូមិ២ | -សំណង់ឈើចាស់ទ្រុឌ<br>ទ្រោម | -សាងសង់សាលាឃុំថ្មី ធ្វើអំពីថ្ម<br>-បំពាក់គ្រឿងសង្ហារឹម |

## ជំពូក៣

## ផែនការប្រើប្រាស់ដីពេលអនាគតអនាគត ឆ្នាំ២០០៩-២០២២

## ៣.១ ស្ថានភាពដី សក្ដានុពលដី និងតម្រូវការដី

### ៣.១.១ ស្ថានភាពដីទូទៅ និងសក្ដានុពល

តាមស្ថានភាពជាក់ស្ដែង ដីឃុំទំនប់រលក ចែកចេញជា ០២ តំបន់សំខាន់ ៗ :

- តំបន់ខ្ពង់រាប និងភ្នំ ជាតំបន់ដែលផ្ដល់សក្ដានុពលលើដីលំនៅដ្ឋានសំរាប់ការរស់នៅរបស់ប្រជាពលរដ្ឋ ដែលស្ថិតនៅស្របតាមបណ្ដោយឆ្នេរសមុទ្រ និងមានសក្ដានុពលលើផ្នែកឧស្សាហកម្មនេសាទ ។

-ឃុំទំនប់រលកទាំងមូលផ្អែកនេសាទសមុទ្រមួយគត់ ដែលជាមុខរបរធំបំផុតសំរាប់ប្រជាពលរដ្ឋ បច្ចុប្បន្ន ការប្រើប្រាស់ដែកនៅមិនទាន់ចំទិលដៅនិងសក្ដានុពលរបស់ដីនៅឡើយទេ ។

សំរាប់អនាគតឃុំទំនប់រលកអាចនឹងមានការអភិវឌ្ឍន៍ ទៅតាមផែនការប្រើប្រាស់ដីរបស់ថ្នាក់ឃុំនិង ចំទិសដៅ ។ តាមការផ្ដល់ទិន្នន័យអំពីផលិតភាពរបស់ដីបង្ហាញអោយឃើញថា ឃុំស្ថិតនៅក្នុងតំបន់ដីដែលមាន ផលិតភាពទាប ។

### ៣.១.២ តម្រូវការដីតាមប្រភេទ

តារាងតម្រូវការដីរតាមប្រភេទ

| ល.រ | ប្រភេទការប្រើប្រាស់ដីពេលអនាគត | ទំហំ ( ហិចតា ) | ចំនួន ( កន្លែង) |
|---|---|---|---|
| ១ | ដីលំនៅដ្ឋានភូមិ | ២៩.០០ | ១ |
| ២ | ចំការដំណាំ | ៤៦.៤០ | ១ |
| ៣ | តំបន់ទេសចរណ៍ធម្មជាតិ | ១១១.៦០ | ១ |
| ៤ | តំបន់សេដ្ឋកិច្ចពិសេស | ១០០៩.០០ | ២ |
| ៥ | តំបន់ឧស្សាហកម្ម | ២៦៨.០០ | ២ |

## ៣.២ ការបែងចែកដីតាមតម្រូវការប្រើប្រាស់

- ដីសំរាប់លំនៅដ្ឋានភូមិ
- ហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម
- ដីសំរាប់តំបន់ទេសចរណ៍ធម្មជាតិ
- ដីសំរាប់តំបន់សេដ្ឋកិច្ចពិសេស
- ដីសំរាប់ចំការដំណាំ
- ដីតំបន់ឧស្សាហកម្ម

### ៣.២.១ <u>ការវិភាគអន្តរៈអំពើ</u> :

-សំរាប់អនាគតឃុំទំនប់រលកនិងមានការកើនឡើង នៅប្រជាពលរដ្ឋក្រោយពេលដែលមានការអភិវឌ្ឍន៍ តំបន់សេដ្ឋកិច្ចពិសេសនិងឧស្សាហកម្ម ដូចនេះ តំរូវការដីសំរាប់សង់លំនៅដ្ឋាននិងមានការកើនឡើង

-ដីលំនៅដ្ឋានរបស់ឃុំទំនប់រលកនិងកើនឡើងនូវស្របតាមឆ្នេរសមុទ្រ និង អាងទឹកសាប ហើយតផ្ជាប់ពីដីលំនៅដ្ឋានបច្ចុប្បន្នដែលមានស្រាប់ ។

-ការបង្កើតតំបន់ទេសចរណ៍ធម្មជាតិនៅក្នុងឃុំទំនប់រលក និងមានសារៈប្រយោជន៍សំរាប់ ប្រជា ពលរដ្ឋក្នុងឃុំទាំងមូល ដើម្បីតាញយកផលពីតំបន់ទេសចរណ៍នេះដូចជា :

ការលក់ដូរផលនេសាទ ដូចជា : ក្តាម មឹក បង្គារ ត្រី ........ សំរាប់ភ្ញៀវទេសចរណ៍

ការកើនឡើងនូវភោជនីយដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់ សំរាប់បំរើអោយភ្ញៀវទេសចរណ៍ ។

-ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ក្នុងឃុំទំនប់រលក មានសារៈប្រយោជន៍សំខាន់ណាស់ ព្រោះឃុំពឹងផ្អែកទៅលើតែផ្អែកនេសាទសមុទ្រតែប៉ុណ្ណោះ តំបន់សេដ្ឋកិច្ចពិសេសនេះ អាចកាត់បន្ថយអ្នកអត់ការងារធ្វើ កាត់បន្ថយការនេសាទនូវសមុទ្រ កាត់បន្ថយអ្នកចេញទៅរកការងារធ្វើនូវក្រៅស្រុក តំបន់សេដ្ឋកិច្ចពិសេសនេះអាចទាញយកកំលាំងពលកម្ម របស់ប្រជាពលរដ្ឋ ក្នុងតំបន់ដើម្បីបំរើការងារតាមតំរូវការ របស់ក្រុមហ៊ុនដែលបានបំរើការ ។

### ៣.២.២ ផែនទីប្រើប្រាស់ដីអនាគត



### ៣.២.៣ ការបរិយាយការប្រើប្រាស់តាមក្បាលដី

**ដីលំនៅដ្ឋានភូមិ**

ក្បាលដីលេខ F1200-01 = 29.00 ហិចតា

ដីនេះមានទំហំ ២៩.00 ហិចតា មានរាងជាចតុកោណស្របតាមឆ្នេរសមុទ្រ តភ្ជាប់ពីភូមិ ១ និងភូមិ ៣ របស់ឃុំទំនប់រលកមានជំរៅប្រហែល ៦00ម៉ែត្រ ដីមិនមានជីជាតិសំរាប់ដំណាំកសិកម្មទេ ។ បច្ចុប្បន្នជា

-ដីចំការដំណាំ ៥.00 ហិចតា

-វាលស្មៅ ៨.00ហិចតា

-ចំការឈើហូបផ្លែ ៩.១0 ហិចតាដីពុំមានជីជាតិ ។ អាចបង្កលក្ខណ:ដល់ការសង់ លំនៅដ្ឋានថ្មី ក្នុងការកើនឡើងរបស់ប្រជាពលរដ្ឋ ដីលំនៅដ្ឋាននេះរីកឡើងស្របតាមឆ្នេរសមុទ្រ និង តភ្ជាប់ពី លំនៅដ្ឋានចាស់ដែលមានស្រាប់ ភូមិ ១ និង ភូមិ ៣ ក្នុងឃុំទំនប់រលក ។

**<u>បញ្ញត្តិក្នុងការប្រើប្រាស់ដី</u>**

- ត្រូវរក្សាទុកដីចំណីផ្លូវតាមច្បាប់កំណត់

-ជំរៅដីសំរាប់សង់លំនៅដ្ឋាន មិនអោយលើសពី ១00 ម៉ែត្រ ពីអ័ក្សផ្លូវ ។

**ដីតំបន់ទេសចរណ៍ធម្មជាតិ**

ក្បាលដីលេខ : F6500-01 = 111.60 ហិចតា

បច្ចុប្បន្នជា

| | | |
|---|---|---|
| -ដីវាលស្មៅ | ៧៣.៧0 | ហិចតា |
| -ដីខ្សាច់ | ៣.២0 | ហិចតា |
| -ដីខ្សាច់ | ៣៤.៧0 | ហិចតា |

ដីមានទំហំ ១១១.៦0 ហិចតា មានរាងជាធ្លា ស្របតាមឆ្នេរសមុទ្រនិងព្រៃកោងកាងដែលមានបណ្តោយប្រមាណ ១៧00 ម៉ែត្រនឹងជំរៅប្រមាណ ៤៥0 ម៉ែត្រ ជាប្រភេទដីខ្សាច់ មិនមានជីវជាតិសំរាប់ប្រកបកសិកម្មទេ ។ ដីនេះមានសក្តានុពលនឹងបង្កលក្ខណ:សំរាប់តែតំបន់ទេសចរណ៍ ធម្មជាតិ ព្រោះវាមានសមុទ្រមានឆ្នេរសំរាប់ភ្ញៀវទេសចរណ៍មកលេងកំសាន្ត តំបន់ទេសចរណ៍ធម្មជាតិនេះស្ថិតនៅភូមិ ១ ក្នុងឃុំទំនប់រលកការ

បង្កើតតំបន់ទេសចរណ៍នៅពេលអនាគតអាចនឹងកាត់បន្ថយភាពខ្វះការងារធ្វើ របស់ប្រជាពលរដ្ឋក្នុងឃុំព្រោះប្រជាពលរដ្ឋ អាចទាញយកផលចំនេញពីតំបន់ទេសចរណ៍ដូចជា :

១.ការលក់ដូរផលនេសាទសមុទ្រ មាន : ក្តាម មឹង បង្គារ ត្រី ...។ល។

២.បំរើការងារនៅតាមភោជនីយដ្ឋាន សណ្ឋាគារ ។

៣.បានរក្សាព្រៃកោងកាងអោយគង់វង្ស នូវថ្ងៃអនាគត ធនធានជលផលនឹងកើនឡើង

**<u>បញ្ញត្តិក្នុងការប្រើប្រាស់ដីរបស់ទេសចរណ៍</u>**

-ត្រូវមានអនុក្រិត រឺ លិខិតអនុញ្ញាតិពីរដ្ឋាភិបាល

-សិក្សាពីផលប៉ះពាល់ ធនធានធម្មជាតិ ។

**តំបន់សេដ្ឋកិច្ចពិសេស**

F7000-01 = 755 .90ហិចតា

បច្ចុប្បន្នជា

-ចំការបោះបង់ដុះស្មៅ ១០៧.៩០ ហិចតា

-ចំការដំណាំ ១៨៧.៤០ ហិចតា

-វាលស្មៅ ៣៤.៩២ ហិចតា

-ព្រៃគម្ពោធ ១២.៥០ ហិចតា

-ចំការព្រៃដាំ ៤១៣.១៨ ហិចតា

F7000-02 = 253.10 ហិចតា

បច្ចុប្បន្នជា

-វាលស្មៅ ២៥៣.១០ ហិចតា

ដីនេះលាតសន្ធឹងតាមបណ្តោយឆ្នេរសមុទ្រ និងព្រៃកថ្មរ៉ុង ប្រវែងប្រមាណ ១៧០០ម៉ែត្រនឹងជំរៅ ប្រមាណ ៤៥០ ម៉ែត្រ បច្ចុប្បន្នជាដី ចំការបោះបង់ដុះស្មៅ ចំការដំណាំ វាលស្មៅ ព្រៃគម្ពោធ ចំការព្រៃដាំ វាលស្មៅ ។

ការបាត់បង់ដីនេះ ពាក់ពន្ធ័ទៅនឹងសារៈប្រយោជន៍ដូចខាងក្រោម :

-ដីពុំមានជីវជាតិសំរាប់ការធ្វើកសិកម្ម

-ឃុំពុំមានកសិដ្ឋានចិញ្ចឹមសត្វ ។

-ការបង្កើតតំបន់សេដ្ឋកិច្ចពិសេសទាំងពីខាងលើនេះពេលអនាគតប្រជាពលរដ្ឋក្នុងឃុំទំនប់រលកអាចទទួលបានផលពីតំបន់សេដ្ឋកិច្ចពិសេស ដូចជា :

-ការកាត់បន្ថយអ្នកអត់ការងារធ្វើ

-កាត់បន្ថយការនេសាទសមុទ្រ

-កាត់បន្ថយអ្នកទៅធ្វើការងារខាងក្រៅស្រុក

-និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ស្របតាមគោលនយោបាយរបស់ សម្តេច អគ្គមហាសេនា បតី តេជោហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

តំបន់សេដ្ឋកិច្ចទាំងពីកន្លែងនេះ ស្ថិតភូមិ ១ ក្នុងឃុំទំនប់រលក គឺតំបន់ទី ០១ របស់ក្រុមហ៊ុន ................. ដែលកំពុងសិក្សា សំរាប់ធ្វើហេដ្ឋារចនាសម្ព័ន្ធផ្សេងៗក្នុងតំបន់របស់ខ្លួន ។

តំបន់សេដ្ឋកិច្ចពិសេសទី០២របស់ក្រុមហ៊ុនអ៊ែតវ៉ូត.............យោងតាមអនុក្រិតលេខ .......... ចុះថ្ងៃ.................ខែ..................ឆ្នាំ....................... សំរាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ។

**តំបន់ឧស្សាហកម្ម**

- F7100-01 = 222.10 ហិចតា

បច្ចុប្បន្នជា

-វាលស្មៅ ១៧៥.១០ ហិចតា

-ចំការព្រៃដាំ ៤៧.00 ហិចតា

-F7100-02 = 45.90 ហិចតា

បច្ចុប្បន្នជា

-វាលស្មៅ ៤៥.៩០ហិចតា

ការបាត់បង់ដីនេះពាក់ពន្ធ័នៅនិងសារៈប្រយោជន៏ដូចខាងក្រោម :

-នៅក្នុងឃុំ ទំនប់រលកពុំមានកសិដ្ឋានចិញ្ចឹមសត្វ

-ដីពុំមានជីជាតិសំរាប់ ដាំដំណាំ ដែលអាចទទួលផលបាន ដូចនេះតម្រូវការ អោយដីខាងលើនេះ អភិវឌ្ឍន៍ទៅជា តំបន់ឧស្សាហកម្មព្រោះតំបន់នេះមានសក្តានុពលអាចធ្វើជារោងចក្រ សហគ្រាស សំរាប់អនាគត ។

ការបង្កើតតំបន់ឧស្សាហកម្មទាំងពីរកន្លែងក្នុងឃុំគឺមានប្រយោជន៏ដូចជា :

-ការកាត់បន្ថយ អ្នកអត់ការងារធ្វើ

-ការកាត់បន្ថយការនេសាទសមុទ្រព្រោះប្រជាពលរដ្ឋបច្ចុប្បន្នពឹងផ្អែកទៅលើមុខរបរនេសាទតែប៉ុណ្ណោះ ។

**បញ្ហាតិក្នុងការប្រើប្រាស់ដី**

-មានអនុក្រិត្យរបស់រាជរដ្ឋាភិបាល

-សិក្សាអំពីផលប៉ះពាល់ដល់ធនធានធម្មជាតិ

## ការសន្និដ្ឋាន

ក្រោយពីប្រមូលបានទិន្នន័យទាំងអស់ដែលមាននៅក្នុងឃុំសំរាប់ការសរសេរនិងចងក្រងជាសៀវភៅរៀបចំ ផែនការប្រើដីធ្លីថ្នាក់ឃុំសង្កាត់នាពេលបច្ចុប្បន្ន និងពេលអនាគត យើងបានដឹងពីសក្តានុពលដែលមាននៅក្នុងឃុំ ជាពិសេសយើងបានធ្វើផែនទីសំរាប់បច្ចុប្បន្ននិងផែនទីប្រើប្រាស់ដីសំរាប់ពេលអនាគតដែលបានបង្ហាញពីភាព សមស្រប របស់ដីធ្លី និងធនធានដែលមាននៅក្នុងឃុំ និងការគិតទុកជាមុនចំពោះកំណើនរបស់ប្រជាពលរដ្ឋ និងតំរូវការដីធ្លីសំរាប់ ១៥ ឆ្នាំ ខាងមុខ។

ដូចជាការកើនឡើងនៅដីសំរាប់សង់លំនៅដ្ឋាន ដីកសិកម្ម ដីសំរាប់តំបន់សេដ្ឋកិច្ចពិសេស ទេសចរណ៏ធម្មជាតិ និងហេដ្ឋារចនាសម្ព័ន្ធទូទាំងឃុំ ។មិនតែប៉ុណ្ណោះការរៀបចំផែនការប្រើប្រាស់ដីធ្លីថ្នាក់ឃុំសំរាប់ពេលអនាគត ដោយផ្អែក តាមស្ថានភាពដីធ្លីសក្តានុពលដីនិងតំរូវការដីព្រមទាំងធ្វើការវិភាគអំពីអន្តរអំពើរបស់ដី ដែលត្រូវយកទៅប្រើប្រាស់ ក្នុងពេលអនាគត ។

ការរៀបចំផែនការប្រើប្រាស់ដីធ្លី គឺស្របតាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីកាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋនិងធ្វើការទាក់ទាញ ដល់អ្នកវិនិយោគទុន ជាតិ និងអន្តរជាតិ សំរាប់ធ្វើការអភិវឌ្ឍន៍នៅក្នុងឃុំប្រកបដោយចីរភាព ។

ឃុំទំនប់រលក, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០០៩

**មេឃុំ**

**ឡាច. ចិន**

**បានឃើញ និង ពិនិត្យត្រឹមត្រូវ**

គោរពជូន ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្ត
និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តព្រះសីហនុ

"ដើម្បីមេត្តាពិនិត្យ និងសំរេច"

ស្ទឹងហាវ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩

**អភិបាលនៃគណៈអភិបាលស្រុក**

**និងជាប្រធានក្រុមការងារដីរដ្ឋ**

**ស្រុកស្ទឹងហាវ**

**ឆាយ សុគន្ធជា**

**បានឃើញ និង ឯកភាព**

ព្រះសីហនុ ថ្ងៃទី ០៤ ខែ ០៩ ឆ្នាំ ២០១០

**អភិបាលនៃគណៈអភិបាលខេត្ត**

**និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ**

**ខេត្តព្រះសីហនុ**

ស្បោង_សារ៉ាត

# ឧបសម្ព័ន្ធ១

ការពិពណ៌នា អំពីស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

**ដីលំនៅដ្ឋាន :**

ដីលំនៅដ្ឋានរបស់ ឃុំ ទំនប់រលក គឺជាដីដែលស្ថិតនៅស្របតាមដងផ្លូវ តិរៈវិថី សម្តេច ហ៊ុនសែន និង ស្របតាមឆ្នេរសមុទ្រនៅតាមស្ថានភាពដីខ្ពង់រាប ។ ដីលំនៅដ្ឋានទាំងនេះសង់រាបជាជួរតាមការរៀបចំរបស់អាជ្ញាធរដែនដីដែលមានផ្ទៃដីទំហំ ១០ម៉ែត្រ គុណ អោយ ៣០ ម៉ែត្រ ក្នុង ១គ្រួសារ នៅជុំវិញបរិវេនដីលំនៅដ្ឋានរបស់ប្រជាពលរដ្ឋនីមួយៗ មានចំការឈើហូបផ្លែនិងដំណាំ ដូចជា : ខ្នុរ ចេក ដូង ស្វាយ ទឹកដោះគោ ស្លឹកគ្រៃ ជី ម្ទេស ត្រសក់ ស្ពៃ ។ល ។

ដោយឡែកដីលំនៅដ្ឋានមួយចំនួនបានសង់តាមមាត់ព្រែកឆ្នេរសមុទ្រ សំរាប់ប្រជាពលរដ្ឋដែលមានមុខរបរនេសាទ ដើម្បីងាយស្រួលក្នុងការចតទូក នេសាទព្រោះប្រជាពលរដ្ឋ ក្នុងឃុំទំនប់រលក មានមុខរបជាអ្នកនេសាទ រហូតដល់ ៨០ភាគរយ ។

**ចំការឈើហូបផ្លែ**

ដីចំការឈើហូបផ្លែក្នុងឃុំទំនប់រលក មានដូចជា ដូង ខ្នុរ ស្វាយ ទឹកដោះគោ ល្មុត ដែលអាចទទួលផលបានប៉ុន្តែនាពេលបច្ចុប្បន្នត្រូវបានបោះបង់ចោលការដាំដុះដំនាំប្រភេទនេះដោយពុំមានទីផ្សារ និងដីមិនមានជីជាតិសំរាប់ប្រកបរបរផ្នែកកសិកម្មតម្រូវការអាចប្រជាពលរដ្ឋមួយចំនួនបានលក់ដីជាកម្មសិទ្ធិរបស់ខ្លួនទៅអោយអ្នកវិនិយោគដើម្បីធ្វើការអភិវឌ្ឍន៏តំបន់ សេដ្ឋកិច្ចពិសេស ។

**សមុទ្រ**

សមុទ្រនៅក្នុងឃុំទំនប់រលក មានសក្តានុពលដល់សារៈប្រយោជន៏ ដល់ប្រជាពលរដ្ឋដែលជាអ្នក ប្រកបរបនេសាទ ព្រោះសមុទ្រនេះមានធនធានជលផលដូចជា : បង្គារ ខ្យង ក្តាម មឹក បង្កង ត្រី គ្រប់ប្រភេទ ។ ផលនេសាទដែលប្រជាពលរដ្ឋប្រមូលបានពីសមុទ្រយកទៅលើទីផ្សារក្នុងស្រុកដូចជា : ផ្សារស្ទឹង ហាវ ផ្សារទំនប់រលក ផ្សារខេត្តព្រះសីហនុ និងនាំចេញទៅលក់នូវប្រទេសក្រៅទៀត ដូចជា : វៀតណាម ថៃ ជាដើម ។

## ឧបសម្ព័ន្ធ២

### ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដីបច្ចុប្បន្ន

| ល.រ | ចំណាត់ថ្នាក់នៃការគ្រប់គ្រង និងកាន់កាប់ដី | | ក្រឡាផ្ទៃ(ហិចតា) |
|---|---|---|---|
| | តាមច្បាប់អនុញ្ញាត និងតួនាទី | តាមចំណាត់ថ្នាក់ដីរដ្ឋ ឯកជន | |
| ១ | ដីតំបន់ព្រៃបៃតង | ដីសាធារណៈរបស់រដ្ឋ | ១០៥០(យោងតាមទិន្នន័យឃុំ) |
| ២ | ដីព្រៃកោងកាង | ដីសាធារណៈរបស់រដ្ឋ | ១០៨.៣០៤៩ |
| ៣ | សមុទ្រ | ដីសាធារណៈរបស់រដ្ឋ | ៩.១៤៨៩ |
| ៤ | ខ្សាច់ | ដីសាធារណៈរបស់រដ្ឋ | ៣.៣៣១១ |

## ឧបសម្ព័ន្ធ៣

## បញ្ហាពាក់ពន្ធ័ក្នុងការប្រើប្រាស់ដី

| បញ្ហា | ទីតាំង | មូលហេតុ | ដំណោះស្រាយ |
|---|---|---|---|
| ១-ព្រៃឈើបាត់បង់ | ភូមិ ១ | -ទន្រ្ទានយកដី | -ដាំកូនឈើឡើងវិញ<br>-បង្កើតសហគមន៍ព្រៃឈើ |
| ២-ធនធានជលផលថយចុះ | ភូមិ១-២-៣-៤ | -ឧបករណ៍នេសាទ<br>ខុសច្បាប់តម្រូវការកើន | -ផ្សព្វផ្សាយច្បាប់ជលផល<br>-បង្កើនការគាំទ្រសហគមន៍នេសាទ |
| ៣-បាត់បង់ព្រៃលិចទឹក | ភូមិ ១ | -ទន្រ្ទានយកដី | -ពង្រឹងការអនុវត្តន៍ច្បាប់<br>-ដាំព្រៃកោងកាងឡើងវិញ<br>-បង្កើនការគាំទ្រសហគមន៍ការពារព្រៃលិចទឹក |
| ៤-បាត់បង់តំបន់ឆ្នេរ | ភូមិ១-២-៣-៤ | -ទន្រ្ទានយកដីឆ្នេរពីសំណាក់អ្នកមានលុយ<br>មានអំណាចមួយចំនួនតូច | -រៀបចំតំបន់ឆ្នេរទេសចរណ៍<br>-បង្កើតសហគមន៍តំបន់ឆ្នេរទេសចរណ៍ធម្មជាតិ<br>-រិតបន្តឹងច្បាប់បរិស្ថាន<br>-ផ្សព្វផ្សាយច្បាប់ អនុវត្តន៍ច្បាប់បន្ថែម<br>-ត្រូវអនុវត្តច្បាប់ផ្តន្ទាទោស |
| ៥-ខ្វះផ្លូវល្អធ្វើដំណើរ | ទូទាំងឃុំ | -ខ្វះលូបង្ហូរកាត់ផ្លូវ<br>-ខ្វះប្រឡាយ<br>-ភ្លៀងហូរច្រោះ | -ស្តារ-ជួសជុលផ្លូវទាំងអស់<br>-សាងសង់ផ្លូវថ្មី២ខ្សែបន្ថែម(៥.១)<br>-ធ្វើផ្លូវកៅស៊ូបន្ត |

| | | | |
|---|---|---|---|
| | | -ខ្វះស្ពាន | -ធ្វើផ្លូវបេតុងបន្ត<br>-សាងសង់លូអក្សរអ៊ិយកាត់ផ្លូវ<br>-ស្ពាន១ ( ៥.២ ) |
| ៦-ទំនាស់ដីធ្លី | ទូទាំងឃុំ | -គ្មានបណ្ណ័សំគាល់កម្មសិទ្ធិ | -ផ្តល់បណ្ណ័កម្មសិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពន្ធ័<br>-ផ្សព្វផ្សាយច្បាប់ភូមិបាល |
| ៧-បញ្ហាកាកសំណល់ | ទាំង៤ភូមិ | -ខ្វះការគ្រប់គ្រងកាកសំណល់<br>-ខ្វះការយល់ដឹង<br>-គ្មានកណ្តែងចាក់កាកសំណល់ | -ផ្សព្វផ្សាយការយល់ដឹងពីផលប៉ះពាល់បរិស្ថាន<br>-រកទីតាំងចាក់កាកសំណល<br>-រកអ្នកម៉ៅការទទួលសេវាប្រមូលកាកសំណល់ |
| ៨-ខ្វះអាគារសិក្សា | ភូមិ៤ | -សិស្សកើនឡើង | -សាងសង់អាគារសិក្សា១ខ្នង២ជាន់១២បន្ទប់<br>-សាងសង់បង្គន់អនាមយ័សាលា៦បង្គន់<br>-សាងសង់ទីចាត់ការសាលា១ខ្នង<br>-សាងសង់អគារសិក្សាមតេយ្យ១ខ្នងមាន៥បន្ទប់ |
| ៩-ការបង្ហូរកាកសំណល់រឹងរាវចូលសមុទ្រ | ភូមិ១-២-៣-៤ | -ផ្ទះសង់តាមឆ្នេរ លើទឹកសមុទ្រ<br>-បង្គន់ | -ផ្សព្វផ្សាយពង្រឹងការអនុវត្តន៏ច្បាប់បរិស្ថាន<br>-ផ្សព្វផ្សាយអប់រំពីអនាមយ័បរិស្ថាន |
| ១០-ការចោលកាកសំណល់ចូលក្នុងទឹកសមុទ្រ | ទាំង៤ភូមិ | -ខ្វះប្រពន្ធ័ប្រមូលកាកសំណល់ | -រៀបចំប្រពន្ធ័ប្រមូលកាកសំណល់ ។ |
| ១១-សាលាឃុំទ្រុឌទ្រោម | ភមិ១ ភូមិ២ | -សំណង់ឈើចាស់ទ្រុឌទ្រោម | -សាងសង់សាលាឃុំថ្មី ធ្វើអំពីថ្ម<br>-បំពាក់គ្រឿងសង្ហារឹម |

# ឧបសម្ព័ន្ធ៤

## កំណត់ត្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និងយុទ្ធសាស្ត្រ

| តម្រូវការនៃការអភិវឌ្ឍន៍ | ប្រភពឯកសារ | គោលដៅនៃការអភិវឌ្ឍន៍ | យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ | សកម្មភាពជាអាទិភាព |
|---|---|---|---|---|
| -ចង់បានអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់និងតម្លៃសមរម្យ | | -មានអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់និងតម្លៃថោក | -តបណ្តាញអគ្គិសនីពីទីរួមខេត្តមក | -តបណ្តាញឱ្យមានគ្រប់គ្រាន់ |
| -ចង់ឱ្យមានជំនាញពិតប្រាកដ | | -ធ្វើឱ្យប្រជាពលរដ្ឋមានជីវភាពល្អប្រសើរឡើង | បង្កើនជំនាញដើម្បីរកប្រាក់ចំណូលក្នុងការរស់នៅសមរម្យ | -បណ្តុះបណាលវិជ្ជាជីវៈ |
| ចង់បានធនធានជលផលកើនឡើង | | -ប្រជាពលរដ្ឋមានត្រីសាច់សំរាប់ហូបគ្រប់មានជីវភាពប្រសើរ | -បង្កើនចំណេះដឹងជំនាញដល់ប្រជាពលរដ្ឋតាមការបណ្តុះបណ្តាល<br>-ការពារព្រៃលិចទឹក កោងកាង | -ផ្សព្វផ្សាយច្បាប់ជលផល<br>-ដាំកូនកោងកាង<br>-ទប់ស្កាត់ការនេសាទខុសច្បាប់ |
| ចង់បានបរិស្ថានល្អអនាម័យនិងសោភ័ណភាព | | ប្រជាពលរដ្ឋគ្រប់រូបមានការយល់ដឹងពីផលប៉ះពាល់បរិស្ថាននិងសុខភាព | ជំរុញនឹងបង្កើនការយល់ដឹងនិងយកចិត្តទុកដាក់គ្រប់គ្រងកាកសំណល់ជាលក្ខណៈគ្រួសារ | ផ្សព្វផ្សាយអំពីផលប៉ះពាល់បរិស្ថាន<br>-រកកន្លែងចាក់កាកសំណល់<br>-ធ្វើឡដុតកាកសំណល់ |
| -ចង់បានអគារសិក្សាបន្ថែម<br>-លើកកំពស់សុខភាពកុមារ | | -ឆ្នាំ២០០៨-២០១២សិស្សមានអាគារសិក្សាគ្រប់គ្រាន់<br>-កុមារត្រូវបានលើកកំពស់មានឱកាសបញ្ចេញមតិកុមារបានរៀន | -ពង្រឹងគុណភាពអប់រំមានសាលារៀន គ្រប់កំរិតសិក្សា<br>-បង្កើនការអប់រំផ្សព្វផ្សាយពីផលប៉ះពាល់សុខភាពលើកំលាំងពលកម្មកុមារ | -សាងសង់អាគារសិក្សា<br>-ផ្តល់គ្រូបង្រៀន<br>-ផ្សព្វផ្សាយច្បាប់ស្តីពីការជួញដូរកុមារផ្សព្វផ្សាយច្បាប់ស្តីពីសិទ្ធិកុមារនិង |

| | | | | |
|---|---|---|---|---|
| | | | | កេងប្រវ័ញ្ចលើពលកម្មកុមារ |
| ចង់បានកន្លែងសេវាផ្តល់សុខភាពជូនប្រជាពលរដ្ឋ | | -ប្រជាពលរដ្ឋបានទទួលសេវាសុខភាព ជិតមូលដ្ឋានរបស់ខ្លួន នាថ្ងៃអនាគត | គំរោងសាងសង់ប៉ុស្តិ៍សុខភាព | សាងសង់ប៉ុស្តិ៍សុខភាពក្នុងឃុំនិងមានសេវាជាប្រចាំ |
| មានអត្តសញ្ញាណបណ្ណ័ប្រជាពលរដ្ឋកម្ពុជា | | -ប្រជាពលរដ្ឋគ្រប់រូបត្រូវមានអត្តសញ្ញាណសំគាល់ខ្លួន | ប្រជាពលរដ្ឋមានអត្តសញ្ញាណសំគាល់ប្រើប្រាស់ | ធ្វើអត្តសញ្ញាណបណ្ណ័ជូនដល់ប្រជាពលរដ្ឋគ្រប់រូប |
| មានបណ្ណ័សំគាល់សិទ្ធិកាន់កាប់ដីធ្លី | | -កម្មសិទ្ធិរបស់ប្រជាពលរដ្ឋមានបណ្ណ័កាន់កាប់ត្រឹមត្រូវ | ធ្វើឱ្យប្រសើរឡើងនូវការសំគាល់ដីនិងកាត់បន្ថយទំនាស់ដីធ្លី | -ផ្តល់បណ្ណ័សំគាល់សិទ្ធិកាន់កាប់ដីធ្លីជូនប្រជាពលរដ្ឋ |
| ចង់បានផ្លូវល្អសំរាប់ធ្វើដំណើរ | -ផែនការអភិវឌ្ឍន៍៥ឆ្នាំ ២០០៨-២០១២ | ឆ្នាំ២០០៨-២០១២ ប្រជាពលរដ្ឋនៅក្នុងមានផ្លូវល្អធ្វើដំណើរ | -ស្តាឡើងវិញនូវប្រពន្ធ័ហេដ្ឋារចនាសម្ពន្ធ័ដឹកជញ្ជូននៅមូលដ្ឋានឱ្យទាន់ពេលវេលា | -សាងសង់ផ្លូវកៅស៊ូ<br>-សាងសង់ផ្លូវបេតុង |
| -វគ្គផ្សព្វផ្សាយច្បាប់ បរិស្ថាន ព្រៃឈើ-ជលផល<br>-ឱ្យប្រជាជនយល់ដឹងអំពីច្បាប់ព្រៃឈើ សត្វព្រៃមច្ឆាជាតិ | | ឱ្យប្រជាពលរដ្ឋយល់ដឹងអំពីច្បាប់<br>-ប្រជាជនអនាគតគាត់និងយល់ច្បាស់ពីច្បាប់គ្រប់គ្រងធនធានធម្មជាតិ | -ផ្សព្វផ្សាយការគ្រប់គ្រង<br>-ធនធានធម្មជាតិនិងការដាំកូនឈើឡើងវិញដើម្បីតម្រូវការក្នុងការប្រើប្រាស់នៅពេលអនាគត | -វគ្គផ្សព្វផ្សាយពីច្បាប់បរិស្ថាន<br>-ច្បាប់ព្រៃឈើ<br>-ច្បាប់ជលផល<br>-ផ្សព្វផ្សាយច្បាប់ការពារសត្វព្រៃ<br>-ពីសារៈប្រយោជន៏ព្រៃឈើ<br>-គំរោងធ្វើចង្រ្កានសន្សំអុស<br>-ធ្វើប៉ាណូផ្សព្វផ្សាយការពារសត្វព្រៃ និងមច្ឆាជាតិ |

| | | | | |
|---|---|---|---|---|
| ចង់ឱ្យមានផ្លាកថ្នាំពុលជាអក្សរខ្មែរ | | -ប្រជាជនក្នុងឃុំទំនប់រលកនិងកាត់បន្ថយការប្រើប្រាស់ថ្នាំពុល | -ទប់ស្កាត់ការនាំចូលថ្នាំពុលដែលប្រើភាសារបរទេស | -ផ្សព្វផ្សាយដល់ក្រុមហ៊ុនផលិតនិងក្រុមហ៊ុននាំថ្នាំពុលចូល |
| ចង់បានព្រំប្រទល់ឃុំច្បាស់លាស់<br>-ចង់បានផ្សព្វផ្សាយច្បាប់ភូមិបាល | | -ប្រជាជននិងរដ្ឋអំណាចខេត្តនិងសហការណ៍ធ្វើផែនទីព្រំប្រទល់ឱ្យបានច្បាស់លាស់ | -ឃុំមានព្រំប្រទល់ពាក់ពន្ធ័សហការនិងមន្ទីរជំនាញធ្វើការកំណត់ព្រំប្រទល់តាមការឯកភាពគ្នា | -សហការធ្វើព្រំប្រទល់ឡើងវិញ<br>-ផ្សព្វផ្សាយច្បាប់ភូមិបាល |

# ឧបសម្ព័ន្ធ៥

## បញ្ជីគំរោង ឬសកម្មភាពសំខាន់របស់ឃុំ ក្នុងរយៈពេល១៥ឆ្នាំ

| ល.រ | គំរោង ឬសកម្មភាព | លទ្ធផលគ្រោង | | ផែនការប្រើប្រាស់ដីធ្លី១៥ឆ្នាំ | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ចំនួនឯកត្តា | ឯកត្តា | ៥ឆ្នាំទី១ | ៥ឆ្នាំទី២ | ៥ឆ្នាំទី៣ | |
| ២.៦.១ | គំរោងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត | | | | | | |
| | ២.៦.១.១ គំរោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត | | | | | | |
| | ១.១ ផ្លូវថ្នល់ធ្វើពីបេតុង | ៧៥00 | ម៉ែត្រ | ២៥00 | ២៥00 | ២៥00 | |
| | ១.១.១ ផ្លូវក្រាលកៅស៊ូ | ៦000 | ម៉ែត្រ | ២000 | ២000 | ២000 | |
| | ១.១.២ ផ្លូវក្រាលគ្រួសក្រហម | ១៥000 | ម៉ែត្រ | ៥000 | ៥000 | ៥000 | |
| | ១.២ ប្រពន្ធ័ស្រោចស្រព | | | | | | |
| | ១.២.១ ប្រឡាយបង្ហូរទឹកស្អុយ | ១៥000 | ម៉ែត្រ | ៥000 | ៥000 | ៥000 | |
| | ១.២.២ ប្រឡាយជុំវិញអាងទឹក | ២000 | ម៉ែត្រ | ២000 | ២000 | ២000 | |
| | ១.៣ ហេដ្ឋារចនាសម្ពន្ធ័ផ្សេងៗទៀត | | | | | | |
| | ១.៣.១ ចំនួនស្ពានថ្ម | 0២ | កន្លែង | 0១ | 0១ | 0១ | |
| ២.៦.២ | ២.៦.២.៣ គំរោងផ្នែកបង្កើតជំនាញនិងមុខរបរ | | | | | | |
| | ២.៦.២.៣.២ វគ្គបណ្ដុះបណ្ដាលពំពីការប្រើប្រាស់ដី | ៧៥ | វគ្គ | ២៥ | ២៥ | ២៥ | |
| | ២.៦.២.៣.៣វគ្គបណ្ដុះបណ្ដាលអំពីការកែប្រែគុណភាពដី | ១៥ | វគ្គ | 0៥ | 0៥ | 0៥ | |